**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ៨១ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## ការដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញព្រះរាជក្រមលេខ នស/រកម/០២១០/០០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីអស្សាមិករណ៍

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៤/៣៧៣ ចុះថ្ងៃទី២៩ ខែមីនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា ២ និងមាត្រា ៥ នៃព្រះរាជក្រឹត្យលេខ នស/រកត/០៥១២/៤៦៣ ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

-បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

-បានឃើញអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-បានឃើញអនុក្រឹត្យលេខ ៧៦ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០១៥ ស្តីពីការកែសម្រួលមាត្រា ៣០ មាត្រា ៣៤ មាត្រា ៣៨ មាត្រា ៥០ មាត្រា ៦៦ មាត្រា ៧៤ និងមាត្រា ៨២ នៃអនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១៥ ស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន

-យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ

**សម្រេច**

**មាត្រា ១.-**

ត្រូវបានដាក់ឱ្យប្រើប្រាស់ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ដែលមានចក្ខុវិស័យដល់ឆ្នាំ ២០៣០ ដូចមានឧបសម្ព័ន្ធភ្ជាប់ជាមួយអនុក្រឹត្យនេះ។

**មាត្រា ២.-**

ផែនការរៀបចំដែនដីខេត្តព្រះសីហនុអាចធ្វើការកែសម្រួលក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំម្តង តាមករណីចាំបាច់នៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម។ ការកែសម្រួលផែនការរៀបចំដែនដីខេត្តព្រះសីហនុមុនពេលកំណត់ អាចប្រព្រឹត្តទៅបានក្នុងករណីដែលមានតម្រូវការចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬផលប្រយោជន៍ជាតិ។

ការកែសម្រួលផែនការរៀបចំដែនដីខេត្តព្រះសីហនុ ត្រូវអនុវត្តតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

**មាត្រា ៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា ៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ ប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ពុធ ១ កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៣ ខែមិថុនា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ដើម្បីចុះហត្ថលេខា
**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់**
**និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ**

**ជា សុផារ៉ា**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ៤
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ការដាក់ឱ្យអនុវត្តផែនការរៀបចំដែនដីខេត្តព្រះសីហនុ ចក្ខុវិស័យឆ្នាំ២០៣០
ដោយអនុក្រឹត្យលេខ..៧៦ អនក្រ.បក..ចុះថ្ងៃទី..៣ ... ១..កើត ខែអស្សុជ...ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២
ត្រូវនឹងថ្ងៃទី..១៧... ខែ..តុលា.. ឆ្នាំ២០១៨

# ផែនការរៀបចំដែនដីខេត្តព្រះសីហនុ
## ចក្ខុវិស័យឆ្នាំ២០៣០

**មាតិកា**

**ទំព័រ**


**១- សេចក្តីផ្តើម** ........................................ **១**

**២- ចក្ខុវិស័យ** ........................................ **២**

២.១- ក្របខណ្ឌសេដ្ឋកិច្ចសង្គម ........................................ ២

២.២- ចក្ខុវិស័យ ........................................ ៣

**៣- គោលបំណងនិងគោលដៅ** ........................................ **៣**

៣.១- គោលបំណង ........................................ ៣

៣.២- គោលដៅ ........................................ ៣

**៤- យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍** ........................................ **៤**

៤.១- យុទ្ធសាស្ត្ររៀបចំដែនដីនិងនគរូបនីយកម្ម ........................................ ៤

៤.១.១- យុទ្ធសាស្ត្ររៀបចំដែនដី ........................................ ៤

៤.១.២- យុទ្ធសាស្ត្រអភិវឌ្ឍនគរូបនីយកម្ម ........................................ ៥

៤.២- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម ........................................ ៧

៤.២.១- លើកកម្ពស់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងវិស័យឧស្សាហកម្មបច្ចេកវិទ្យាទំនើប សម្រាប់ការនាំចេញ ........................................ ៧

៤.២.២- លើកកម្ពស់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃផលិតផលក្នុងស្រុកនិងតម្លៃបន្ថែម ដោយផ្អែកលើធនធានសមុទ្រ កសិកម្ម និងវារីវប្បកម្ម ........................................ ៨

៤.២.៣- លើកកម្ពស់ កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់អភិវឌ្ឍវិស័យឧស្សាហកម្ម.... ៩

៤.២.៤- លើកកម្ពស់ការអប់រំ អភិវឌ្ឍធនធានមនុស្ស ទំនាក់ទំនងវិជ្ជាជីវៈ និងទីផ្សារពលកម្មដើម្បីទាក់ទាញការវិនិយោគនិងគាំទ្រដល់វិស័យឧស្សាហកម្ម ........................................ ៩

៤.២.៥- កំណត់តំបន់ភស្តុភារកម្ម តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្ម ........................................ ១០

៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍ ........................................ ១០

៤.៣.១- ការអភិវឌ្ឍផលិតផលទេសចរណ៍ ........................................ ១០

៤.៣.២- ការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍ ........................................ ១១

៤.៣.៣- សុវត្ថិភាពទេសចរណ៍និងផលប៉ះពាល់អវិជ្ជមាន ........................................ ១១

៤.៣.៤- ការអភិវឌ្ឍធនធានមនុស្ស ........................................ ១២

៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម ........................................ ១២

៤.៤.១- អ័ក្សនៃការអភិវឌ្ឍរវាងរាជធានីភ្នំពេញ-ខេត្តព្រះសីហនុ ........................................ ១២

៤.៤.២- អ័ក្សនៃការអភិវឌ្ឍតាមផ្លូវអាយស្វ័យយានតភ្ជាប់រវាងខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែបនិងរាជធានីភ្នំពេញ ........................................ ១២

៤.៤.៣- អ័ក្សនៃការអភិវឌ្ឍគាំទ្រពាណិជ្ជកម្មតាមព្រំដែនតភ្ជាប់រវាងខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប ........................................ ១៣

៤.៤.៤- ផ្លូវថ្នល់....................១៣
៤.៤.៥- ផ្លូវសមុទ្រ....................១៤
៤.៤.៦- ផ្លូវអាកាស....................១៤
៤.៤.៧- រ៉ែ ប្រេងកាត ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា....................១៤
៤.៤.៨- សមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធ....................១៥
៤.៥- យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត....................១៥
៤.៥.១- ការផ្គត់ផ្គង់ទឹកស្អាតនៅក្រុង និងទីប្រជុំជន....................១៥
៤.៥.២- ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ....................១៦
៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាននិងធនធានធម្មជាតិ....................១៦
៤.៦.១- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង....................១៦
៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ....................១៦
៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន....................១៦
៤.៦.៤- វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ....................១៧
៤.៧- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម....................១៧
**៥- ផែនការសកម្មភាព....................១៩**
៥.១- ការអភិវឌ្ឍដែនដី និងនគរូបនីយកម្ម....................១៩
៥.២- ផែនការសកម្មភាពតាមវិស័យ....................២០
៥.៣- គម្រោងអាទិភាព....................២១
៥.៣.១-ការរៀបចំដែនដី និងនគរូបនីយកម្ម....................២១
៥.៣.២-ការលើកកម្ពស់វិស័យឧស្សាហកម្មនិងភស្តុភារកម្ម....................២២
៥.៣.៣-ការអភិវឌ្ឍទេសចរណ៍....................២២
៥.៣.៤-ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ....................២៣
៥.៣.៥-ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន....................២៣
**៦- ធនធានហិរញ្ញវត្ថុ....................២៤**
**៧- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ....................២៤**
៧.១- យន្តការ....................២៤
៧.២- ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត....................២៥
៧.៣- ភារកិច្ច នីតិវិធី និងគោលការណ៍....................២៥
**៨- សេចក្តីសន្និដ្ឋាន....................២៦**
**សន្ទានុក្រម....................២៨**
**ឯកសារឧបសម្ព័ន្ធ....................២៩**

**១- សេចក្តីផ្តើម**

ស្ថិតក្នុងបរិការណ៍សុខសន្តិភាព ឯកភាពទឹកដី ឯកភាពជាតិ ស្ថិរភាពនយោបាយរឹងមាំ ការប្រកាន់ខ្ជាប់ឥតងាករេនូវគោលការណ៍លទ្ធិប្រជាធិបតេយ្យ នីតិរដ្ឋ និងការគោរពសិទ្ធិមនុស្ស នៅក្រោមដំបូលរដ្ឋធម្មនុញ្ញ និងច្បាប់ រាជរដ្ឋាភិបាលបានធានាជាប់ជាប្រចាំនូវប្រក្រតីភាពនៃដំណើរទៅមុខនៃការអភិវឌ្ឍសង្គម សេដ្ឋកិច្ចកម្ពុជា។ រាជរដ្ឋាភិបាលបានបន្តជំរុញការកែទម្រង់ស្ថាប័នឱ្យមានសន្ទុះថ្មី មុតស្រួច និងកាន់តែស៊ីជម្រៅលើគ្រប់ផ្នែក និងគ្រប់វិស័យ ក្នុងគោលដៅបង្កើន និងកែលម្អការផ្តល់គុណភាពសេវាសាធារណៈ ប្រកបដោយគុណភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព។

ផ្អែកតាមយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ រាជរដ្ឋាភិបាលកម្ពុជាក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវគោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា សំដៅធានាថា ដែនដីនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ត្រូវបានគ្រប់គ្រង ប្រើប្រាស់ ការពារ និងអភិវឌ្ឍ តាមរយៈការធ្វើសមាហរណកម្មនូវផែនការយុទ្ធសាស្ត្ររៀបចំដែនដី និងការធ្វើឱ្យរលូននូវវិធាននិងឧបករណ៍ចាំបាច់នានាតាមវិស័យប្រកបដោយភាពសុខដុមរមនានៅតាមតំបន់ភូមិសាស្ត្រនីមួយៗ។

ក្នុងគោលដៅធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិ ព្រមទាំងការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុ ប្រកបដោយចីរភាព គណៈកម្មការអន្តរក្រសួងដែលបច្ចុប្បន្នជាគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានរៀបចំនូវ **ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ចក្ខុវិស័យ ឆ្នាំ២០៣០** ដើម្បីជាមូលដ្ឋានក្នុងការគ្រប់គ្រងនិងតម្រង់ទិសអភិវឌ្ឍដែនដីខេត្តព្រះសីហនុទាំងមូល ស្របតាមចក្ខុវិស័យនៃគោលនយោបាយដីធ្លីជាពិសេស គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ទេសចរណ៍ និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀត។

ដោយមើលឃើញថាសក្តានុពលតំបន់ឆ្នេរសមុទ្រមានសារៈសំខាន់ដល់សេដ្ឋកិច្ចកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាបានកែលម្អនិងពង្រីកកំពង់ផែស្វយ័តក្រុងព្រះសីហនុ ដែលជាកំពង់ផែសមុទ្រទឹកជ្រៅតែមួយគត់របស់ប្រទេសកម្ពុជា និងអាកាសយានដ្ឋានអន្តរជាតិកងកេង ខេត្តព្រះសីហនុ ឱ្យក្លាយទៅជាច្រកចេញចូលអន្តរជាតិដ៏ទំនើប និងមានប្រសិទ្ធភាព សម្រាប់ផ្សារភ្ជាប់ទំនាក់ទំនងជាមួយនឹងសកលលោក។

ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ត្រូវបានកសាងឡើងដោយផ្អែកលើកត្តាទីតាំងភូមិសាស្ត្រនៃតំបន់ឆ្នេរសមុទ្រកម្ពុជា កត្តាធនធានធម្មជាតិ បរិស្ថាន ប្រវត្តិសាស្ត្រ វប្បធម៌ និងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ស្របតាមគោលនយោបាយ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តសំខាន់ៗមួយចំនួនពាក់ព័ន្ធនឹងការរៀបចំដែនដីនិងនគរូបនីយកម្មនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដូចជា ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំ

ទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផល ច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ និងអនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជាជាដើម។

ចក្ខុវិស័យនៃផែនការនេះមានលក្ខណៈទូលំទូលាយគ្របដណ្តប់ទាំងទិដ្ឋភាពគតិយុត្ត និងបច្ចេកទេសសម្រាប់ធ្វើការសម្របសម្រួលរវាងវិស័យនានាដែលជាកម្លាំងចលករសេដ្ឋកិច្ច សំដៅធ្វើការតម្រង់ទិសការអភិវឌ្ឍប្រកបដោយចីរភាព ឆ្លើយតបទៅនឹងកំណើនប្រជាសាស្ត្រ តម្រូវការក្នុងការប្រើប្រាស់ដី ការអភិវឌ្ឍលំនៅឋាន និងការបង្កើតទីក្រុងតូច មធ្យម ធំគ្រប់កម្រិតក្នុងពេលបច្ចុប្បន្ននិងទៅអនាគត ដោយធានាបាននូវការការពារធនធានដី ប្រព័ន្ធអេកូឡូស៊ី បរិស្ថាន និងធនធានធម្មជាតិ ដែលអាចរងការបំផ្លាញដោយសារសកម្មភាពអភិវឌ្ឍរបស់មនុស្សឬដោយសារការប្រែប្រួលអាកាសធាតុ ដូចជាការបំភាយឧស្ម័នផ្ទះកញ្ចក់ ការកើនឡើងនៃកម្តៅក្នុងទីក្រុង របបទឹកភ្លៀងមិនទៀងទាត់ ទឹកជំនន់ ភាពរាំងស្ងួត និងខ្យល់ព្យុះជាដើម។

## ២- ចក្ខុវិស័យ

### ២.១- ក្របខណ្ឌសេដ្ឋកិច្ចសង្គម

ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ត្រូវបានរៀបចំឡើងដោយបានសិក្សាប្រមូលនិងវិភាគទិន្នន័យរូបវន្ត ទិន្នន័យសេដ្ឋកិច្ច ទិន្នន័យសង្គម ទិន្នន័យបរិស្ថាន ទិន្នន័យប្រជាសាស្ត្រ និងការស្រង់មតិ សមស្របតាមអនុក្រឹត្យស្តីពីនគរូបនីយកម្ម រាជធានី ក្រុង និងទីប្រជុំជន គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា និងគោលនយោបាយដីធ្លី "សៀវភៅ ស ដីធ្លី"។

ដើម្បីកំណត់ចក្ខុវិស័យ នៃផែនការរៀបចំដែនដីខេត្តព្រះសីហនុដល់ឆ្នាំ ២០៣០ ក្របខណ្ឌសេដ្ឋកិច្ចសង្គម ត្រូវបានសិក្សាវិភាគតាមបែបវិទ្យាសាស្ត្រ ដោយផ្អែកតាមរបាយការណ៍ជាតិស្តីពីលទ្ធផលចុងក្រោយនៃជំរឿនទូទៅនូវប្រជាភស្ត្ររបស់ប្រទេសកម្ពុជាឆ្នាំ២០០៨ របស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ តាមរយៈការសិក្សាខាងលើនេះ ខេត្តព្រះសីហនុដែលមានផ្ទៃដី ២ ៥២៨,៥៨ គីឡូម៉ែត្រក្រឡា ចំនួនប្រជាជននៅឆ្នាំ ២០០៨ មានចំនួន ២២១ ៣៩៦ នាក់ នៅឆ្នាំ២០១៨ មានចំនួន ២៩២ ៤០៤ នាក់ ហើយនៅឆ្នាំ២០៣០ នឹងកើនដល់ ៣៦០ ៦៨៤ នាក់។ ជាមួយគ្នានេះ ការបែងចែកកម្លាំងពលកម្មតាមវិស័យសេដ្ឋកិច្ចសម្រាប់ខេត្តព្រះសីហនុនៅឆ្នាំ២០០៨ ចំនួនប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មមាន ៩០ ០៣២ នាក់ (៤៧,១៧%) ក្នុងវិស័យឧស្សាហកម្មមាន ២៨ ៤០១ នាក់ (១៤,៨៨%) និងក្នុងវិស័យសេវាកម្មមាន ៧២ ៤៣៤ នាក់ (៣៧,៩៥%) ហើយរំពឹងថានៅឆ្នាំ២០៣០ ចំនួនប្រជាជនដែលធ្វើការក្នុងវិស័យកសិកម្មនឹងមានការថយចុះមកត្រឹម ៥៧ ៤៦២ នាក់ (១៨%) វិស័យឧស្សាហកម្មនឹងមានការកើនឡើងដល់ចំនួន ១២៧ ៦៩៤ នាក់ (៤០%) និងវិស័យសេវាកម្មនឹងមានការកើនឡើងដល់ចំនួន ១៣៤ ០៧៩ នាក់ (៤២%)។

**២.២- ចក្ខុវិស័យ**

ចក្ខុវិស័យដល់ឆ្នាំ២០៣០ នៃផែនការរៀបចំដែនដីខេត្តព្រះសីហនុ គឺរៀបចំនិងអភិវឌ្ឍ **«ខេត្តព្រះសីហនុ ជាប៉ូលអភិវឌ្ឍជាតិប្រកបដោយចីរភាពនៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈការអភិវឌ្ឍទីក្រុងទំនើប រមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណងច្រកចេញចូលអន្តរជាតិ មជ្ឈមណ្ឌលកំណើនជាតិ មជ្ឈមណ្ឌលភស្តុភារកម្មជាតិដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាននិងទីផ្សារសកលលោក និងមជ្ឈមណ្ឌលឧស្សាហកម្មផលិតកម្មបែបបច្ចេកវិទ្យាទំនើប ដែលមានសុខដុមនីយកម្មជាមួយនឹងបរិស្ថានរស់នៅល្អប្រសើរ»** ដោយផ្អែកលើសក្តានុពលសេដ្ឋកិច្ច ទីតាំងភូមិសាស្ត្រនៃតំបន់ឆ្នេរសមុទ្រកម្ពុជា និងក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ ព្រមទាំងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ គោលនយោបាយជាតិស្តីពីការរៀបចំដែនដីនៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយអភិវឌ្ឍវិស័យឧស្សាហកម្មកម្ពុជា និងគោលនយោបាយតាមវិស័យសំខាន់ៗជាច្រើនទៀតរបស់រាជរដ្ឋាភិបាល។

## ៣- គោលបំណងនិងគោលដៅ

ដើម្បីសម្រេចចក្ខុវិស័យខាងលើ ផែនការរៀបចំដែនដីខេត្តព្រះសីហនុមានគោលបំណងនិងគោលដៅដូចខាងក្រោម៖

**៣.១- គោលបំណង**

គោលបំណងនៃផែនការរៀបចំដែនដីខេត្តព្រះសីហនុ គឺ៖

- តម្រង់ទិសការប្រើប្រាស់ដី ធនធានធម្មជាតិ និងការរៀបចំនគរូបនីយកម្មប្រកបដោយប្រសិទ្ធភាព ចីរភាព និងសមធម៌ដើម្បីគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ធានាសន្តិសុខស្បៀង កិច្ចការពារជាតិ និងលំនឹងធម្មជាតិ
- តម្រង់ទិសការកែលម្អនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ រូបវន្ត សង្គម និងសេដ្ឋកិច្ច ឆ្ពោះទៅរកសមាហរណកម្មល្អ ក្នុងក្របខណ្ឌជាតិ តំបន់ និងអន្តរជាតិ
- លើកកម្ពស់អត្តសញ្ញាណវប្បធម៌ជាតិ កិច្ចការពារបរិស្ថាន ការអភិវឌ្ឍបៃតង និងបង្ការទប់ស្កាត់គ្រោះមហន្តរាយប្រកបដោយប្រសិទ្ធភាព។

**៣.២- គោលដៅ**

គោលដៅនៃផែនការរៀបចំដែនដីខេត្តព្រះសីហនុ គឺ៖

- កំណត់យុទ្ធសាស្ត្រអភិវឌ្ឍដែនដីនិងនគរូបនីយកម្មប្រកបដោយចីរភាពនិងតុល្យភាព
- ជំរុញកំណើនសេដ្ឋកិច្ច អភិវឌ្ឍធុរកិច្ច និងទាក់ទាញការគាំទ្រការវិនិយោគ
- គ្រប់គ្រង ការពារ ប្រើប្រាស់ អភិវឌ្ឍដីនិងធនធានធម្មជាតិ ដោយកំណត់ឱ្យបានច្បាស់លាស់ជាមុននូវតំបន់សម្រាប់ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សង្គម សេដ្ឋកិច្ច បរិស្ថាន និងវប្បធម៌

- ធ្វើសមាហរណកម្មការគ្រប់គ្រងដីនិងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនិងសេវាកម្មក្រុង ស្រុក និងខេត្ត ឱ្យស្របទៅនឹងលក្ខខណ្ឌនិងកត្តាតម្រូវនៃការរៀបចំដែនដីទូទាំងប្រទេស
- លើកកម្ពស់ជីវភាពប្រជាជនក្នុងខេត្តឱ្យកាន់តែប្រសើរឡើងនិងកាត់បន្ថយជាអតិបរមានូវគម្លាតរវាងតំបន់ទីក្រុងនិងជនបទ
- ទប់ស្កាត់និងបង្ការហានិភ័យនៃគ្រោះធម្មជាតិនិងការប្រែប្រួលអាកាសធាតុ
- ធ្វើសមាហរណកម្មអត្តសញ្ញាណវប្បធម៌ជាតិនិងធម្មជាតិទៅក្នុងការអភិវឌ្ឍស្របតាមទីតាំងភូមិសាស្ត្រ។

## ៤- យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍

ដើម្បីសម្រេចបាននូវចក្ខុវិស័យ គោលបំណង និងគោលដៅខាងលើ ផែនការរៀបចំដែនដីខេត្តព្រះសីហនុបានកំណត់យុទ្ធសាស្ត្រតម្រង់ទិសអភិវឌ្ឍន៍សំខាន់ៗ ដូចខាងក្រោម៖

### ៤.១- យុទ្ធសាស្ត្ររៀបចំដែនដីនិងនគរូបនីយកម្ម

#### ៤.១.១- យុទ្ធសាស្ត្ររៀបចំដែនដី

- អភិវឌ្ឍខេត្តព្រះសីហនុជាប៉ូលអភិវឌ្ឍជាតិតំបន់ឆ្នេរសមុទ្រទិសនិរតីនៃព្រះរាជាណាចក្រកម្ពុជាប្រកបដោយចីរភាព
- អភិវឌ្ឍខេត្តព្រះសីហនុឱ្យក្លាយទៅជាតំបន់សេដ្ឋកិច្ចពិសេសពហុបំណង
- លើកកម្ពស់អ័ក្សអភិវឌ្ឍភ្នំពេញ-ព្រះសីហនុ (ភ្នំពេញ-កំពង់ស្ពឺ-ព្រះសីហនុ) តាមបណ្តោយផ្លូវអាស៊ានលេខ១១ និងតាមផ្លូវជាតិលេខ៣
- ជំរុញការរៀបចំអ័ក្សអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា (កោះកុង-ព្រះសីហនុ-កំពត-កែប) តាមបណ្តោយផ្លូវអាស៊ានលេខ១២៣
- ជំរុញការអភិវឌ្ឍក្រុងព្រះសីហនុជាទីក្រុងទំនើប
- កំណត់និងជំរុញការអភិវឌ្ឍតំបន់ទីប្រជុំជនស្ទឹងហាវ ទីប្រជុំជនវាលរេញ ទីប្រជុំជនកែវផុស ទីប្រជុំជនកំពង់សិលា ទីប្រជុំជនរាម ទីប្រជុំជនកោះខ្យង និងទីប្រជុំជនត្រង់ចំណុចប្រសព្វរវាងផ្លូវជាតិលេខ៤ និងផ្លូវជាតិលេខ៤៨
- ជំរុញអភិវឌ្ឍនិងអភិរក្សតំបន់ឆ្នេរសមុទ្រ កោះ ប្រជុំកោះ ឧទ្យានសមុទ្រ និងរមណីយដ្ឋានទេសចរណ៍ធម្មជាតិខេត្តព្រះសីហនុជារមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក
- រៀបចំឱ្យមានសារមន្ទីរសមុទ្រ នៅតំបន់ពយម៉ាចូវ ក្នុងភូមិគរគី ឃុំបិទត្រាំង ស្រុកព្រៃនប់
- រៀបចំតំបន់អភិវឌ្ឍទេសចរណ៍កែច្នៃនិងទេសចរណ៍ធម្មជាតិនៅតំបន់ឆ្នេរសមុទ្រនៃស្រុកព្រៃនប់
- រៀបចំតំបន់អភិវឌ្ឍទេសចរណ៍ឆ្នេរសមុទ្រនៅតំបន់ឆ្នេរព្រែកត្រែងនិងឆ្នេរកែវផុសនៃស្រុកស្ទឹងហាវ
- រៀបចំតំបន់ទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍ និងឧទ្យានសមុទ្រនៅតាមកោះ ប្រជុំកោះ និងតំបន់ការពារជុំវិញកោះ៖

- ជំរុញការរៀបចំនិងអភិវឌ្ឍតំបន់អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុនិងតំបន់សុវត្ថិភាពសម្រាប់អាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ
- ជំរុញការរៀបចំនិងអភិវឌ្ឍតំបន់កំពង់ផែដែលជាច្រកចេញចូលអន្តរជាតិ និងតំបន់សុវត្ថិភាពសម្រាប់កំពង់ផែពាណិជ្ជកម្មនិងផែទេសចរណ៍
- ជំរុញការរៀបចំនិងអភិវឌ្ឍ តំបន់ភស្តុភារកម្មដែលមានទីតាំងជាប់នឹងកំពង់ផែ តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្ម
- កំណត់ទីតាំងតំបន់ទីក្រុង តំបន់ឧទ្យានជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ការពារធនធានទឹក តំបន់ការពារនិងអភិរក្ស តំបន់រមណីយដ្ឋានទេសចរណ៍ តំបន់អាទិភាពសម្រាប់ការស្នាក់នៅ។ល។
- ជំរុញការគ្រប់គ្រងទីជំរាលប្រកបដោយនិរន្តរភាពតាមរយៈការធ្វើចំណាត់ថ្នាក់ដីព្រៃរដ្ឋ ការពង្រឹងដល់ការគ្រប់គ្រងតំបន់ការពារ ឧទ្យានជាតិ និងសហគមន៍ព្រៃឈើ និងការការពារទេសភាពតាមមាត់ទឹកទាំងទឹកប្រៃនិងទឹកសាប រួមមាន សមុទ្រ ព្រែក ស្ទឹង អូរ និងបឹងជាដើម
- កំណត់គោលដៅអភិវឌ្ឍតំបន់ឧស្សាហកម្មបច្ចេកវិទ្យាទំនើប តំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្មកែច្នៃផលិតផលក្នុងស្រុក នៅស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងស្រុកកំពង់សិលា ដោយត្រូវយកចិត្តទុកដាក់អំពីផលប៉ះពាល់ដល់តំបន់ការពារបរិស្ថាន ធនធានធម្មជាតិ កសិកម្ម និងតំបន់អភិវឌ្ឍទេសចរណ៍
- កំណត់គោលដៅអភិវឌ្ឍតំបន់ទេសចរណ៍ធម្មជាតិនិងកសិទេសចរណ៍ ពិសេសនៅតាមឆ្នេរសមុទ្រ ព្រៃកោងកាង ព្រៃលិចទឹក ព្រែក ស្ទឹង អូរ បឹង ទឹកជ្រោះ តំបន់ភ្នំ នៅស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងស្រុកកំពង់សិលា ដោយផ្សារភ្ជាប់នឹងប្រភពទឹកធម្មជាតិនិងគម្របព្រៃឈើ
- រៀបចំប្លង់គោលប្រើប្រាស់ដីស្រុកស្ទឹងហាវ ស្រុកព្រៃនប់ និងស្រុកកំពង់សិលា ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព តុល្យភាព និងប្រសិទ្ធភាព
- កំណត់ការប្រើប្រាស់ដីជាពីរប្រភេទ គឺប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់
- រៀបចំបង្កើតទីលានចាក់សំរាមថ្មីដោយប្រើបច្ចេកវិទ្យានិងប្រព័ន្ធដំណើរការ ដើម្បីធានាបាននូវអនាម័យល្អ ដែលមានទីតាំងស្ថិតនៅ ភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ចម្ងាយ ២ គីឡូម៉ែត្រខាងជើងផ្លូវជាតិលេខ៤។

### ៤.១.២- យុទ្ធសាស្ត្រអភិវឌ្ឍនគរូបនីយកម្ម

- រៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីក្រុងព្រះសីហនុ ដើម្បីជំរុញការអភិវឌ្ឍក្រុងព្រះសីហនុជាក្រុងទំនើប
- រៀបចំប្លង់គោលប្រើប្រាស់ដីស្រុកស្ទឹងហាវ ស្របតាមទស្សនទានជាទីក្រុងឧស្សាហកម្មបៃតងអាស៊ាននាពេលអនាគត

- រៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីទីប្រជុំជនវាលរេញ ទីប្រជុំជនកែវផុស ទីប្រជុំជនកំពង់សិលា ទីប្រជុំជនរាម ទីប្រជុំជនកោះខ្យង និងទីប្រជុំជនផ្លូវបំបែកស្រែអំបិល និងរៀបចំប្លង់លំអិតនគរូបនីយកម្មដើម្បីធានការអភិវឌ្ឍទីក្រុងប្រកបដោយចីរភាព
- កំណត់គោលដៅអភិវឌ្ឍន៍កោះជាតំបន់ទេសចរណ៍ធម្មជាតិ និងត្រូវការពារធនធានធម្មជាតិនិងរក្សាគម្របព្រៃឈើដែលមានស្រាប់នៅលើកោះឱ្យបានយ៉ាងតិច ៦០% នៃផ្ទៃដីកោះសរុប និងត្រូវរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងសំណល់រឹងនិងរាវ ដើម្បីធានាបាននូវគុណភាព និងចីរភាពបរិស្ថាន។ ការអភិវឌ្ឍដីនៅលើកោះ ត្រូវមានសន្ទស្សន៍ប្រើប្រាស់ដីអតិបរិមាស្មើ ១,៥ ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍អតិបរមាគិតជាភាគរយមិនឱ្យលើសពី ៣៥% ហើយផ្ទៃដីដែលនៅសល់ត្រូវរៀបរៀបចំដាំដើមឈើនិងធ្វើជាសួនបៃតងយ៉ាងតិចយ៉ាងតិច ៥០ % និងកម្ពស់សំណង់អតិបរមាមិនលើសពី ៣ ជាន់ (កម្ពស់អគារអតិបរមា១២ម៉ែត្រ)
- គ្រប់គ្រង ធ្វើអត្តសញ្ញាណកម្ម និងរៀបចំកំណត់ប្រភេទឆ្នេរសមុទ្រស្របតាមសក្តានុពលដើម្បីគាំទ្រដល់ការអភិវឌ្ឍ និងការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ ប្រកបដោយចីរភាព និងសមធម៌
- គ្រប់គ្រង ការពារ និងរៀបចំផែនការប្រើប្រាស់ដីចំណីឆ្នេរសមុទ្រជាលំហសាធារណៈ និងផ្ទៃបៃតងសម្រាប់សាធារណជន និងទេសចរ
- ជម្រុញរៀបចំផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រស្របតាមសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំប្លង់លម្អិតនគរូបនីយកម្មដើម្បីគ្រប់គ្រង និងការពារទេសភាព សោភណភាព និងបរិស្ថានតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ ស្របតាមសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- ជំរុញការអនុវត្តសារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- កំណត់តំបន់និងបទប្បញ្ញត្តិប្រើប្រាស់ដីសម្រាប់ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់៖

  ក-ប្រភេទដីអាចសាងសង់បានត្រូវបែងចែកជា ១). តំបន់លំនៅឋាន ២). តំបន់ពាណិជ្ជកម្ម ៣). តំបន់ឧស្សាហកម្ម ៤). តំបន់ចម្រុះ ៥). តំបន់ទេសចរណ៍ ៦). តំបន់ដឹកជញ្ជូន ៧). តំបន់រដ្ឋបាលនិងសេវាសាធារណៈ ៨). តំបន់លំហសាធារណៈនិងផ្ទៃបៃតង ៩). តំបន់វប្បធម៌និងសាសនា និង ១០). តំបន់ផ្សេងៗស្របតាមទីតាំងភូមិសាស្ត្រខេត្តព្រះសីហនុ។

  ខ-ប្រភេទដីកម្រិតការសាងសង់ត្រូវបែងចែកជា ១). តំបន់កសិកម្ម ២). តំបន់ព្រៃឈើ តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម និងតំបន់ព្រៃលិចទឹក ៣). តំបន់ការពារធនធានទឹកមានជាអាទិ៍ ផ្ទៃសមុទ្រ ដៃសមុទ្រ ព្រែក ស្ទឹង បឹង អូរ និងអាងស្តុកទឹកធម្មជាតិ ៤). តំបន់ការពារមានជាអាទិ៍ ឧទ្យានជាតិព្រះសីហនុរាម តំបន់ដែន

ជីវកសត្វព្រៃ តំបន់ការពារទេសភាព តំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយ តំបន់ជីវៈចម្រុះសមុទ្រ ទឹកសាប តំបន់ការពារបេតិកភណ្ឌធនធានធម្មជាតិសមុទ្រ ឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ តំបន់ឧទ្យានសមុទ្រ និងកោះ ៥).តំបន់របៀងអភិរក្សជីវៈចម្រុះប្រពន្ធ័ការពារធម្មជាតិ ៦).តំបន់ការពារជាតិ។

- ប្លង់គោលនិងផែនការប្រើប្រាស់ដីក្រុង ស្រុក និងទីប្រជុំជន ព្រមទាំងប្លង់លម្អិតនគរូបនីយកម្មតំបន់ឆ្នេរសមុទ្រនិងកោះ ត្រូវសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយសេចក្ដីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ។

### ៤.២- យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

ឈរលើទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជាឆ្ពោះទៅឆ្នាំ២០៣០ ជាពិសេស "យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣" រាជរដ្ឋាភិបាលបានរៀបចំនិងដាក់ចេញនូវ "គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម" ដើម្បីជាមគ្គុទ្ទេសក៍ជំរុញការអភិវឌ្ឍវិស័យឧស្សាហកម្មនៅកម្ពុជា ដែលនឹងរួមចំណែកដល់ការរក្សាកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាពនិងបរិយាបន្ន តាមរយៈការធ្វើពិពិធកម្មសេដ្ឋកិច្ច ការពង្រឹងភាពប្រកួតប្រជែង និងការលើកកម្ពស់ផលិតភាព។

ដើម្បីចូលរួមសម្រេចបាននូវទស្សនវិស័យវែងឆ្ងាយរបស់កម្ពុជា ចក្ខុវិស័យ យុទ្ធសាស្ត្រ និងវិធានការជាក់ស្ដែងគន្លឹះនៃគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ ២០១៥-២០២៥ ខេត្តព្រះសីហនុបានដាក់ចេញនូវយុទ្ធសាស្ត្រសំខាន់មួយចំនួនដូចខាងក្រោម៖

#### ៤.២.១- លើកកម្ពស់ការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស និងវិស័យឧស្សាហកម្មបច្ចេកវិទ្យាទំនើបសម្រាប់ការនាំចេញ

- ការកែលម្អនិងការពង្រឹងគម្រោងតំបន់សេដ្ឋកិច្ចពិសេសរួមមាន៖
  - លើកកម្ពស់ការវិនិយោគក្នុងតំបន់សេដ្ឋកិច្ចពិសេស
  - ពិនិត្យអំពីក្របខណ្ឌលើកទឹកចិត្តសម្រាប់ក្រុមហ៊ុនដែលបោះទីតាំងនៅក្នុងតំបន់សេដ្ឋកិច្ចពិសេសសម្រាប់ទាំងក្រុមហ៊ុនបរទេស ក្រុមហ៊ុនក្នុងស្រុក និងសហគ្រាសធុនតូចនិងមធ្យម
  - ផ្សព្វផ្សាយអំពីច្បាប់ស្ដីពីការវិនិយោគ និងគោលនយោបាយលើកទឹកចិត្តរបស់រាជរដ្ឋាភិបាលដល់ក្រុមហ៊ុនវិនិយោគ និងផែនការរៀបចំដែនដីខេត្តព្រះសីហនុ
  - ធ្វើវិចារណកម្មលើការលើកទឹកចិត្តបន្ថែម ចំពោះគម្រោងវិនិយោគដែលរួមចំណែកក្នុងការបណ្ដុះបណ្ដាលជំនាញ ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍
  - អនុវត្តឱ្យបានម៉ឺងម៉ាត់នូវលក្ខខណ្ឌនិងភារកិច្ចរបស់អ្នកអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស
  - កំណត់និយមន័យច្បាស់លាស់នៃតំបន់កែច្នៃសម្រាប់ធ្វើការនាំចេញ

• ប្រើប្រាស់របបពន្ធគយនៅកន្លែងខុសៗគ្នា

• ចាត់វិធានការ និងជំរុញឱ្យមានការចូលរួមកាន់តែសកម្មថែមទៀត ពីវិស័យឯកជនក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធនៅតាមបណ្ដាតំបន់សេដ្ឋកិច្ចដែលមានស្រាប់ទទួលបានគោលការណ៍ពីរាជរដ្ឋាភិបាលកន្លងមកនៅក្នុងខេត្ត សំដៅធានាឱ្យមានភាពទាក់ទាញ និងការចាប់អារម្មណ៍ពីសំណាក់វិនិយោគិនដែលកំពុងស្វែងរកទីតាំងបង្កើតមូលដ្ឋានផលិតកម្ម។

- ជ្រើសរើសយកប្រភេទនៃឧស្សាហកម្មដែលមានសក្ដានុពលសម្រាប់ទិសដៅនាំចេញ
- លើកកម្ពស់ការប្រកួតប្រជែងរវាងតំបន់សេដ្ឋកិច្ចពិសេស តំបន់ឧស្សាហកម្មនានានៅក្នុងខេត្ត ដោយសិក្សានូវស្វ័យនាការស្ទួលសម្រាប់វាស់ស្ទង់សមិទ្ធិកម្មនៃកិច្ចដំណើរការនៃតំបន់សេដ្ឋកិច្ចពិសេស និងឧស្សាហកម្មទាំងនោះ សម្រាប់ជាលក្ខណៈវិនិច្ឆ័យក្នុងការផ្ដល់ការលើកទឹកចិត្ត
- សិក្សាសួនឧស្សាហកម្មសម្រាប់សហគ្រាសធុនតូច និងមធ្យមសំដៅជំរុញការតភ្ជាប់រវាងសហគ្រាសធំបរទេស និងសហគ្រាសក្នុងស្រុក ពិសេសការចូលរួមក្នុងខ្សែចង្វាក់តម្លៃ និងខ្សែចង្វាក់ផលិតកម្មតំបន់ក្នុងបរិការណ៍នៃសមាហរណកម្មតំបន់
- ពិនិត្យលទ្ធភាពក្នុងការជំរុញការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសធំៗនៅក្នុងខេត្ត និងមានស្ដង់ដារខ្ពស់ដោយប្រើយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។

**៤.២.២- លើកកម្ពស់ការអភិវឌ្ឍវិស័យឧស្សាហកម្មកែច្នៃផលិតផលក្នុងស្រុកនិងតម្លៃបន្ថែម ដោយផ្អែកលើធនធានសមុទ្រ កសិកម្ម និងវារីវប្បកម្ម**

- ពិនិត្យលទ្ធភាពបង្កើតនូវតំបន់កែច្នៃកសិផល ដូចជាតំបន់កែច្នៃផលិតសង្ហារឹម តំបន់កែច្នៃផលិតម្ហូបអាហារពីសមុទ្រ តំបន់កែច្នៃចំណីអាហារសម្រាប់គោលដៅប្រើប្រាស់ក្នុងស្រុកផង និងនាំចេញផង ដោយប្រើប្រាស់យន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ព្រមទាំងផ្ដល់ការលើកទឹកចិត្តចំពោះក្រុមហ៊ុនណាដែលបោះទីតាំងក្នុងតំបន់ទាំងនោះ
- បង្កើតមូលនិធិសម្រាប់ជំរុញការអភិវឌ្ឍផលិតផល បច្ចេកទេសកែច្នៃកសិផល និងអភិវឌ្ឍបច្ចេកទេសដោយភ្ជាប់ទៅនឹងសក្ដានុពលនាំចេញ
- សិក្សាកំណត់នូវមុខទំនិញអាទិភាព ដែលមានសក្ដានុពលកែច្នៃសម្រាប់នាំចេញ ហើយរៀបចំផែនការសកម្មភាពដែលមានលក្ខណៈគ្រប់ជ្រុងជ្រោយ ដោយផ្អែកលើខ្សែចង្វាក់តម្លៃ ដើម្បីកំណត់មូលដ្ឋានគាំទ្រជាក់លាក់ដល់ការអភិវឌ្ឍវិស័យទាំងនោះ
- រៀបចំនូវយន្តការសម្រួលដល់ការនាំចេញកសិផលកែច្នៃ ដោយដោះស្រាយបញ្ហាភស្តុភារកម្ម និងកែលម្អការសម្រួលពាណិជ្ជកម្ម
- បង្កើតការភ្ជាប់ទំនាក់ទំនងដោយផ្ទាល់រវាងអ្នកលក់និងអ្នកទិញ
- ពង្រីកវារីវប្បកម្មសមុទ្រ
- ពង្រីកការធ្វើកសិកម្មសរីរាង្គដែលមានការកាត់បន្ថយការប្រើប្រាស់ជីគីមី សម្រាប់រយៈពេលវែង

- ចងក្រងសៀវភៅសម្រាប់កសិករដើម្បីផ្សព្វផ្សាយអំពីការប្រើប្រាស់ជីគីមីកសិកម្ម
- ចងក្រងគោលការណ៍ណែនាំស្តីពីបរិស្ថាន។

**៤.២.៣- លើកកម្ពស់ កសាង និងកែលម្អហេដ្ឋារចនាសម្ព័ន្ធសម្រាប់អភិវឌ្ឍវិស័យឧស្សាហកម្ម**

- រៀបចំនិងអនុវត្តផែនការមេសម្រាប់ការអភិវឌ្ឍប្រព័ន្ធដឹកជញ្ជូននិងភស្តុភារកម្ម ក្នុងគោលដៅបង្កើតប្រព័ន្ធដឹកជញ្ជូនពហុមធ្យោបាយ និងប្រព័ន្ធភស្តុភារកម្មដែលមានសមាហរណកម្មនិងប្រសិទ្ធភាពខ្ពស់ ពិសេស ផ្តោតលើការតភ្ជាប់ប៉ូលអភិវឌ្ឍ និងអ័ក្សនៃការអភិវឌ្ឍ ភ្នំពេញ-ខេត្តព្រះសីហនុ ឱ្យក្លាយទៅជាអ័ក្សនៃការអភិវឌ្ឍគន្លឹះរបស់ជាតិ តាមរយៈការកសាងផ្លូវល្បឿនលឿនស្តង់ដាអន្តរជាតិ និងការបង្កើតប្រព័ន្ធភស្តុភារកម្មប្រកបដោយប្រសិទ្ធភាព
- បង្កើតយន្តការសម្របសម្រួលការកសាងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន (ផ្លូវថ្នល់ ផ្លូវរថភ្លើង ផ្លូវអាកាស និងកំពង់ផែ) ដោយផ្សារភ្ជាប់ទៅនឹងតំបន់សក្តានុពល និងគោលដៅអភិវឌ្ឍន៍ឧស្សាហកម្មសំខាន់ៗនៅក្នុងខេត្ត
- តម្រង់ទិសការផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាតទៅកាន់តំបន់ឧស្សាហកម្ម និងផលិតកម្មសំខាន់ៗនៅក្នុងខេត្ត ដោយធានាឱ្យបានការផ្គត់ផ្គង់តាមតម្រូវការ និងមានស្ថិរភាព ដែលអនុញ្ញាតឱ្យរោងចក្រអាចគ្រោងផលិតកម្មរបស់ខ្លួនប្រកបដោយប្រសិទ្ធភាព
- រៀបចំនិងអនុវត្តផែនការបញ្ចុះថ្លៃអគ្គិសនី សម្រាប់វិស័យឧស្សាហកម្មនិងពាណិជ្ជកម្ម រួមទាំងការពង្រឹងភាពទុកចិត្តនិងការពង្រីកវិសាលភាពគ្របដណ្តប់នៃការផ្គត់ផ្គង់អគ្គិសនី។

**៤.២.៤- លើកកម្ពស់ការអប់រំ អភិវឌ្ឍធនធានមនុស្ស ទំនាក់ទំនងវិជ្ជាជីវៈ និងទីផ្សារពលកម្មដើម្បីទាក់ទាញការវិនិយោគនិងគាំទ្រដល់វិស័យឧស្សាហកម្ម**

- ជំរុញ និងកសាងមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈលើជំនាញអាទិភាព
- កសាងធនធានមនុស្សដើម្បីជំរុញការអភិវឌ្ឍឧស្សាហកម្មឱ្យមានភាពរឹងមាំ ដោយផ្តល់ការហ្វឹកហាត់លើជំនាញឯកទេស សម្រាប់ដោះស្រាយកង្វះខាតជំនាញលើវិស័យអាទិភាព
- ពង្រឹងសមត្ថភាព និងសហគ្រិនភាពនៃសហគ្រាសធុនតូចនិងមធ្យម ដើម្បីអាចផ្សារភ្ជាប់និងទាញយកផលប្រយោជន៍ពីសក្តានុពលសហគ្រាស និងវិនិយោគបរទេសធំៗស្ថិតក្នុងតំបន់សេដ្ឋកិច្ចពិសេស
- ជំរុញ និងជួយគាំទ្រដល់ការផ្ទេរបច្ចេកវិទ្យា តាមរយៈទស្សនកិច្ចសិក្សានិងការបណ្តុះបណ្តាលពីក្នុងប្រទេស និងបណ្តាប្រទេសនានាជុំវិញសកលលោក
- ជំរុញ និងបន្តពង្រឹងយន្តការទំនាក់ទំនងរវាងត្រីភាគីរួមមានរាជរដ្ឋាភិបាល និយោជក និងនិយោជិតតាមរយៈគណៈកម្មាធិការប្រឹក្សាការងារ ដើម្បីបង្កើនការយោគយល់គ្នា និងការរៀបចំប្រព័ន្ធយន្តការមួយប្រកបដោយប្រសិទ្ធភាព សម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមាដែលស៊ីសង្វាក់ទៅនឹងផលិតភាពការងារ សមស្របតាមលក្ខខណ្ឌសេដ្ឋកិច្ច សង្គម

- ពង្រឹងយន្តការជ្រើសរើសកម្លាំងពលកម្ម ការផ្តល់ព័ត៌មានពីទីផ្សារពលកម្ម និងការបណ្តុះបណ្តាលកម្មករឱ្យយល់ដឹងពីជីវភាព និងសិទ្ធិស្របច្បាប់របស់ខ្លួន
- លើកកម្ពស់សុខុមាលភាពកម្មករ តាមរយៈការជំរុញអនុវត្តគោលនយោបាយលំនៅឋានសម្រាប់កម្មករដែលអនុញ្ញាតឱ្យកម្មករអាចមានលទ្ធភាពធ្វើជាម្ចាស់កម្មសិទ្ធិលំនៅឋានសម្រាប់បង្កើតគ្រួសារ និងមិនធ្វើការផ្លាស់ប្តូរទីលំនៅញឹកញាប់ពេកដែលបង្កើតបញ្ហាខ្វះកម្លាំងពលកម្មក្នុងរយៈពេលខ្លី
- ពង្រឹងយន្តការគ្រប់គ្រងកម្មករជំនាញ ដើម្បីត្រៀមលក្ខណៈឱ្យបានល្អប្រសើរសម្រាប់ឧស្សាហកម្ម និងសហគ្រាសខ្នាតធំ និងសមាហរណកម្មអាស៊ាន
- កៀរគរកម្លាំងពលកម្មតាមរយៈទីភ្នាក់ងារជាតិមុខរបរនិងការងារ។

### ៤.២.៥- កំណត់តំបន់ភស្តុភារកម្ម តំបន់សេដ្ឋកិច្ចពិសេស និងតំបន់ឧស្សាហកម្ម

កំណត់តំបន់ភស្តុភារកម្មដែលមានទីតាំងជាប់នឹងកំពង់ផែដែលជាច្រកចេញ ចូលអន្តរជាតិ។

## ៤.៣- យុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍

ខេត្តព្រះសីហនុមានគោលដៅជាតំបន់ទេសចរណ៍សក្តានុពលជាច្រើន ដែលមានលក្ខណៈពិសេសខុសប្លែកពីគ្នាសម្រាប់ជាគុណប្រយោជន៍ដល់ការបង្កើតផលិតផលទេសចរណ៍ច្រើនប្រភេទ ដើម្បីបំពេញតម្រូវការទីផ្សារទេសចរណ៍ខុសៗគ្នា។ ហេតុដូចនេះ ដើម្បីជំរុញការអភិវឌ្ឍទេសចរណ៍ខេត្តព្រះសីហនុប្រកបដោយចីរភាព ការទទួលខុសត្រូវ និងប្រសិទ្ធភាព ត្រូវយកចិត្តទុកដាក់ផ្តោតសំខាន់លើ៖

### ៤.៣.១- ការអភិវឌ្ឍផលិតផលទេសចរណ៍

- ជំរុញការអភិវឌ្ឍទេសចរណ៍នៅតំបន់ឆ្នេរសមុទ្រកម្ពុជា
- កំណត់តំបន់ទេសចរណ៍ដែលមាននៅក្រុងព្រះសីហនុ តាមឆ្នេរសមុទ្រ តាមកោះ និងអេកូទេសចរណ៍នៅឧទ្យានជាតិរាមនិងតាមកោះ
- ជំរុញការរៀបចំអភិវឌ្ឍផលិតផលទេសចរណ៍ ទាំងវប្បធម៌ ទាំងធម្មជាតិ និងការរៀបចំទេសចរណ៍កែច្នៃ ពិសេសទេសចរណ៍សមុទ្រនិងឆ្នេរឱ្យបានច្រើនប្រភេទនិងច្រើនកន្លែង
- រៀបចំជំរុញការអភិវឌ្ឍផលិតផលសម្បទាទេសចរណ៍ពាក់ព័ន្ធនានា
- រៀបចំនិងអភិវឌ្ឍឆ្នេរសមុទ្រឱ្យមានលក្ខណៈស្តង់ដារ
- ពិនិត្យលទ្ធភាពក្នុងការកំណត់ទីតាំង រៀបចំ និងអភិវឌ្ឍតំបន់ទេសចរណ៍ដែលមានលក្ខណៈជាតំបន់និវេសនដ្ឋានទេសចរណ៍
- ជំរុញក្រុមហ៊ុនវិនិយោគដែលទទួលបានការអនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជារួចហើយឱ្យពន្លឿនការអភិវឌ្ឍរបស់ខ្លួនតាមផែនការមេដែលបានអនុម័ត
- រៀបចំចងក្រងសហគមន៍ដែលមានសក្តានុពលផ្នែកទេសចរណ៍និងអភិវឌ្ឍទេសចរណ៍សមុទ្រ

- ត្រូវរៀបចំនិងគ្រប់គ្រងកំពង់ផែទេសចរណ៍នៅលើដីគោក ដីកោះឱ្យមានសណ្តាប់ធ្នាប់ តាមស្តង់ដារ និងគ្រប់គ្រងមធ្យោបាយដឹកជញ្ជូនភ្ញៀវទេសចររវាងដីគោកនិងកោះឱ្យបានត្រឹមត្រូវ និងធានាសុវត្ថិភាព
- ជំរុញនិងបង្កលក្ខណៈងាយស្រួលដល់ផ្នែកឯកជន ក្នុងការកសាងសម្បទាទេសចរណ៍រួមមាន ការកម្សាន្ត រមណីយដ្ឋាន សណ្ឋាគារ ភោជនីយដ្ឋាន និងទេសចរណ៍ផ្នែកធុរកិច្ច និងពិព័រណ៍ផលិតផលក្នុងស្រុក។

### ៤.៣.២- ការសិក្សាទីផ្សារនិងផ្សព្វផ្សាយទេសចរណ៍

ដើម្បីជំរុញការទាក់ទាញទេសចរណ៍ជាតិនិងអន្តរជាតិមកទស្សនានៅតំបន់ឆ្នេរសមុទ្រ **"តារានៈនាទិសនិរតី"** ជាពិសេស ឆ្នេរសមុទ្រខេត្តព្រះសីហនុឱ្យកាន់តែមានសន្ទុះរីកចម្រើនថែមទៀត គោលការណ៍សំខាន់ៗមួយចំនួនដែលត្រូវបានអនុវត្តមានដូចខាងក្រោមៈ

- រៀបចំមជ្ឈមណ្ឌលផ្សព្វផ្សាយ មណ្ឌលព័ត៌មានទេសចរណ៍ គេហទំព័រតំបន់ឆ្នេរសមុទ្រទាំងមូល ហើយចាំបាច់ត្រូវតភ្ជាប់ជាមួយគេហទំព័ររបស់ក្រសួង ស្ថាប័នរាជរដ្ឋាភិបាល អនុតំបន់ និងតំបន់។ល។
- ជំរុញអភិវឌ្ឍទីផ្សារទេសចរណ៍បៃតង
- ជំរុញកិច្ចសហការជាមួយវិស័យពាក់ព័ន្ធលើការរៀបចំខ្សែទស្សនកិច្ចនៅក្នុងតំបន់ឆ្នេរសមុទ្រកម្ពុជាតភ្ជាប់ទៅប្រទេសជិតខាងនិងជំរុញការផ្សព្វផ្សាយកម្មវិធីនេះ
- ជំរុញកិច្ចសហការជាមួយក្រុមហ៊ុនភាពយន្ត និងក្រុមហ៊ុនផ្សាយពាណិជ្ជកម្ម ដើម្បីរៀបចំព្រឹត្តិការណ៍ទេសចរណ៍នានានៅក្នុងខេត្ត។

### ៤.៣.៣- សុវត្ថិភាពទេសចរណ៍និងផលប៉ះពាល់អវិជ្ជមាន

ការពង្រឹងសុវត្ថិភាពទេសចរណ៍ គឺជាតួនាទីនិងភារកិច្ចរបស់ពលរដ្ឋគ្រប់រូប ធ្វើយ៉ាងណាឱ្យភ្ញៀវពេញចិត្តនិងមានភាពកក់ក្តៅចំពោះការស្នាក់នៅ ការកម្សាន្ត ការទទួលបានសេវាម្ហូបអាហារ និងសេវាកម្មផ្សេងៗ។ ការការពារប្រកបដោយការយកចិត្តទុកដាក់ ការអនុវត្តស្តង់ដារសុវត្ថិភាពតាមមធ្យោបាយដឹកជញ្ជូនតាមរមណីយដ្ឋាន ការការពារសន្តិសុខ សណ្តាប់ធ្នាប់តាមទីសាធារណៈ។ល។ ត្រូវជំរុញការអភិវឌ្ឍទេសចរណ៍ក្នុងខេត្តព្រះសីហនុ ដោយផ្តោតជាសំខាន់ទៅលើៈ

- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ក្នុងការធានាឱ្យបានសន្តិសុខ សុវត្ថិភាពភ្ញៀវ ការដោះស្រាយរាល់បញ្ហាទាំងឡាយដែលបានកើតឡើង ប្រកបដោយការទទួលខុសត្រូវ ដើម្បីលើកកម្ពស់ភាពកក់ក្តៅនៃការទស្សនាខេត្តព្រះសីហនុ
- សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ដើម្បីលុបបំបាត់ឱ្យបាននូវសកម្មភាពលួចឆក់ ការបាត់បង់របស់របររបស់ភ្ញៀវ នៅតាមឆ្នេរសមុទ្រ កន្លែងកម្សាន្ត និងកន្លែងស្នាក់នៅជាដើម។ល។
- ត្រូវយកចិត្តទុកដាក់ការពារសន្តិសុខនិងសណ្តាប់ធ្នាប់តាមទីសាធារណៈ
- សុវត្ថិភាពចំណីម្ហូបអាហារក៏ត្រូវតែយកចិត្តទុកដាក់ ដោយត្រូវជំរុញលើកកម្ពស់អនាម័យម្ហូបអាហារប្រព័ន្ធត្រួតពិនិត្យស្តង់ដាម្ហូបអាហារ និងបញ្ហាជំងឺឆ្លងផ្សេងៗតាមរយៈចំណីអាហារ

- យកចិត្តទុកដាក់និងពង្រឹងសុវត្ថិភាព ប្រព័ន្ធ ឬមធ្យោបាយសង្គ្រោះបន្ទាន់ ជាពិសេស ត្រូវបណ្តុះបណ្តាលមន្ត្រីជំនាញសង្គ្រោះបន្ទាន់ឬសង្គ្រោះបឋម ឆ្នាំឆ្នេរសមុទ្រ ព្រមទាំងមានសម្ភារៈសង្គ្រោះគ្រប់គ្រាន់
- ក្នុងតំបន់កម្សាន្តឆ្នេរសមុទ្រត្រូវគិតនិងរក្សាឱ្យបាននូវសណ្តាប់ធ្នាប់និងចៀសវាងនូវការរំខានទៅដល់ការសម្រាកកម្សាន្តរបស់ភ្ញៀវ
- ការអភិវឌ្ឍនៅក្នុងតំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុ ត្រូវអនុវត្តតាមសារាចរណែនាំលេខ ០១ សរណន ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា។

### ៤.៣.៤-ការអភិវឌ្ឍធនធានមនុស្ស

ការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យទេសចរណ៍ជាកត្តាសំខាន់និងមិនអាចខ្វះបាន នៅក្នុងបរិបទក្នុងខេត្តព្រះសីហនុ ជាពិសេស សមត្ថភាពជំនាញទេសចរណ៍។ ធនធានមនុស្សក្នុងវិស័យទេសចរណ៍ដែលត្រូវផ្តោតការយកចិត្តទុកដាក់មានៈ

- ជំរុញការបណ្តុះបណ្តាលជំនាញដល់និយោជិតបម្រើការងារក្នុងវិស័យទេសចរណ៍ ដោយអនុវត្តតាមបទដ្ឋានទេសចរណ៍
- រៀបចំមជ្ឈមណ្ឌលស្រាវជ្រាវនិងអភិវឌ្ឍទេសចរណ៍នៅតំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុ
- រៀបចំបង្កើតសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទេសចរណ៍នៅតំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុ
- ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងសាធារណៈខេត្តព្រះសីហនុលើវិស័យទេសចរណ៍
- ជំរុញផ្នែកឯកជនឱ្យចូលរួមការបណ្តុះបណ្តាលនៅតាមមូលដ្ឋានអាជីវកម្មទេសចរណ៍។

## ៤.៤- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម

### ៤.៤.១- អ័ក្សនៃការអភិវឌ្ឍរវាងរាជធានីភ្នំពេញ-ខេត្តព្រះសីហនុ

ផ្លូវជាតិលេខ៤ ជាផ្លូវជាតិគោល ដែលមានតួនាទីជាអ័ក្សនៃការអភិវឌ្ឍភស្តុភារកម្ម ឧស្សាហកម្ម និងផ្លូវជាតិលេខ ៣ ជាជម្រើសមួយបន្ថែមទៀតសម្រាប់គាំទ្រដល់ការដឹកជញ្ជូន និងធ្វើដំណើររវាងរាជធានីភ្នំពេញ និងខេត្តព្រះសីហនុ ដែលចាំបាច់ត្រូវអភិវឌ្ឍ និងពង្រីកទទឹងផ្លូវបន្ថែម។

កសាងផ្លូវល្បឿនលឿនបន្ថែម ដើម្បីឆ្លើយតបទៅនឹងតម្រូវការនៃការដឹកជញ្ជូននិងចរាចរណ៍។

រៀបចំ និងសាងសង់កន្លែងឈប់សុំចតតាមបណ្តោយផ្លូវជាតិ ឱ្យមានយ៉ាងតិចមួយកន្លែង ក្នុងចម្ងាយផ្លូវ ៥០ គីឡូម៉ែត្រ។

### ៤.៤.២- អ័ក្សនៃការអភិវឌ្ឍតាមផ្លូវអយស្ម័យយានតភ្ជាប់រវាងខេត្តព្រះសីហនុ ខេត្តកំពត ខេត្តកែប និងរាជធានីភ្នំពេញ

ផ្លូវអយស្ម័យយានដែលតភ្ជាប់ពីកំពង់ផែក្រុងព្រះសីហនុទៅរាជធានីភ្នំពេញ ដោយឆ្លងកាត់ខេត្តកំពត និងខេត្តកែបត្រូវបានស្តារឡើងវិញ។ ផ្លូវអយស្ម័យយាននេះ គួរធ្វើទំនើបកម្មបន្ថែម ដើម្បីក្លាយជាមធ្យោបាយ

ជំនួសឱ្យការដឹកជញ្ជូនតាមរថយន្តដឹកអ្នកដំណើរ ទេសចរ និងទំនិញ ប្រកបដោយប្រសិទ្ធភាព កាត់បន្ថយផលប៉ះពាល់ដល់បរិស្ថាន កាត់បន្ថយការចំណាយ កាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍ និងកាត់បន្ថយពេលវេលា។

**៤.៤.៣- អ័ក្សនៃការអភិវឌ្ឍគាំទ្រពាណិជ្ជកម្មតាមព្រំដែនតភ្ជាប់រវាងខេត្តកោះកុង ខេត្តព្រះសីហនុ ខេត្តកំពត និងខេត្តកែប**

កែលម្អបណ្ដាញផ្លូវគមនាគមន៍ និងការធ្វើឱ្យប្រសើរឡើងនូវមធ្យោបាយត្រួតពិនិត្យរបស់អាជ្ញាធរមានសមត្ថកិច្ច ដើម្បីលើកកម្ពស់ការអភិវឌ្ឍតំបន់ពាណិជ្ជកម្មនិងការដឹកជញ្ជូនឆ្លងកាត់ច្រកព្រំដែនរវាងប្រទេសថៃ និងប្រទេសវៀតណាមឱ្យកាន់តែមានប្រសិទ្ធភាព។

**៤.៤.៤- ផ្លូវថ្នល់**

យុទ្ធសាស្ត្រស្ដារអភិវឌ្ឍនិងការពារបណ្ដាញផ្លូវថ្នល់និងហេដ្ឋារចនាសម្ព័ន្ធខេត្តព្រះសីហនុ មានដូចខាងក្រោម៖

- រៀបចំនិងកែលម្អផ្លូវឧស្សាហកម្មនិងផ្លូវទេសចរណ៍ ដោយកំណត់ផ្លូវជាតិលេខ៤ និងផ្លូវសម្ដេចសង្ឃ ទេព វង្ស និងតិវិថីសម្ដេចហ៊ុន សែន ភ្ជាប់មកកំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាផ្លូវបម្រើដល់វិស័យឧស្សាហកម្ម។ ដោយឡែកចាប់ពីផ្លូវបំបែកផ្លូវសម្ដេចសង្ឃ ទេព វង្ស តាមបណ្ដោយផ្លូវជាតិលេខ៤ ឆ្ពោះទៅក្រុងព្រះសីហនុជាផ្លូវបម្រើដល់វិស័យទេសចរណ៍។ បន្ថែមពីនេះទៀត ត្រូវពង្រីកផ្លូវជាតិលេខ៤និងអភិវឌ្ឍផ្លូវផ្សេងទៀតដែលអាចទៅតំបន់កណ្ដាលក្រុងព្រះសីហនុ ដោយពិចារណាទៅលើការកម្រិតចរាចរណ៍នាពេលអនាគត
- ស្ដារនិងអភិវឌ្ឍផ្លូវចំនួន៤ភ្ជាប់ពីផ្លូវជាតិលេខ៤ទៅតំបន់កណ្ដាលក្រុងព្រះសីហនុ ដើម្បីសម្រួលការធ្វើដំណើរនិងទេសចរ ក្នុងនោះមាន៖ ១).ពីផ្លូវជាតិលេខ៤ ត្រង់ចំណុចភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុ ទៅវិថីមិត្តភាពនិងវិថីឯករាជ្យ ២).ពីផ្លូវជាតិលេខ៤ ត្រង់ចំណុចអូរត្រាវទៅវិថីមិត្តភាព និងវិថីអូរឈើទាល ៣).ពីផ្លូវជាតិលេខ៤ ត្រង់ចំណុចសាលាឃុំបិតត្រាំងកាត់ពយម៉ាចូវឆ្ពោះទៅវិថីស្របឆ្នេរអូរត្រេះនិងវិថីឆ្នេរអូរឈើទាល ៤).ពីផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ៤៥ កាត់ស្របតាមបណ្ដោយឆ្នេរចំការដូងចេងហេងភ្ជាប់ទៅពយម៉ាចូវ
- ពង្រីកផ្លូវពីភូមិ៣ សង្កាត់លេខ១ ទៅតំបន់ទំនប់រលក
- សិក្សានិងកសាងផ្លូវតាមបណ្ដោយឆ្នេរសមុទ្រពីទីប្រជុំជនស្រុកស្ទឹងហាវ ទៅទីប្រជុំជនកែវផុស ភ្ជាប់ទៅឃុំជ្រោយស្វាយ ស្រុកស្រែអំបិល
- សិក្សា និងកសាងផ្លូវវាងថ្មីពីផ្សារស្រុកកំពង់សិលា ឆ្ពោះមកផ្លូវព្រែកក្រាញ់ ភូមិសាមគ្គី ស្រុកព្រៃនប់ ឆ្ពោះមកផ្លូវជាតិលេខ៣
- សិក្សា និងកសាងផ្លូវខ្សែក្រវ៉ាត់ស្របតាមបណ្ដោយឆ្នេរសមុទ្រពីភូមិអុង ឃុំរាម កាត់ព្រែកទឹកសាបដោយស្ពាន មកទីប្រជុំជនកោះខ្ចង ឆ្ពោះទៅស្ពានកំពង់ស្មាច់ ផ្លូវជាតិលេខ៣

- រៀបចំកសាង និងកែលម្អផ្លូវស្របតាមបណ្តោយឆ្នេរសមុទ្រឱ្យមានគុណភាព និងសោភណភាព ស្របតាមគោលការណ៍អភិវឌ្ឍបៃតង និងឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក
- កែលម្អ និងស្តារព្រែក អូរ ផ្លូវទឹកដែលភ្ជាប់ទៅសមុទ្រ ដោយរៀបចំសួនច្បារ ការដាក់ភ្លើងបំភ្លឺ គុណភាពទឹក ឱ្យមានសោភណភាព គុណភាពបរិស្ថានល្អ និងសកម្មភាពរស់រវើក សមស្របជាឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក
- កែលម្អ និងស្តារផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ៣ ផ្លូវជាតិលេខ៤៥ និងផ្លូវក្រវាត់ក្រុង ចិញ្ចើមផ្លូវ កំណត់ប្រភេទដើមឈើ រៀបចំសួនច្បារតាមបណ្តោយផ្លូវ ការដាក់ភ្លើងបំភ្លឺ ផ្លាកសញ្ញាចរាចរ ផ្លាកផ្សព្វផ្សាយពាណិជ្ជកម្ម ឱ្យមានសោភណភាព សណ្តាប់ធ្នាប់ គុណភាពបរិស្ថានល្អ សមស្របជាខ្លោងទ្វារនិងអ័ក្សមេនៃក្រុងប៉ូលអភិវឌ្ឍជាតិ
- កែលម្អ និងរៀបចំមហាវិថី វិថី អនុវិថី ផ្លូវថ្មើរជើង បណ្តាញផ្លូវ លំហសាធារណៈ កំណត់ប្រភេទ និងដាំដើមឈើ រៀបចំសួនសាធារណៈ សួនកុមារ ទីលានកីឡា កន្លែងកម្សាន្ត អភិវឌ្ឍផ្ទៃបៃតងនៅក្នុងក្រុងព្រះសីហនុស្របទៅតាមតំបន់ប្រើប្រាស់ដី ឱ្យមានសោភណភាព សណ្តាប់ធ្នាប់ល្អ បរិស្ថានរស់នៅប្រកបដោយសុខភាពល្អ សម្រាប់មនុស្សទាំងអស់គ្នា
- រៀបចំឱ្យមានកន្លែងសាធារណៈសម្រាប់សម្រាកកម្សាន្តក្នុងពិធីផ្សេងៗ
- រៀបចំ និងអភិវឌ្ឍចំណតរថយន្តសាធារណៈ នៅតំបន់ក្បាលឆាយ ក្នុងភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុ ស្របតាមបទដ្ឋានទីក្រុងទំនើប
- លើកកម្ពស់ និងផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរណ៍តាមផ្លូវគោក។

### ៤.៤.៥- ផ្លូវសមុទ្រ

- ស្តារ អភិវឌ្ឍ និងធ្វើទំនើបកម្មកំពង់ផែស្វយ័តក្រុងព្រះសីហនុនិងកំពង់ផែមួយចំនួនទៀតដែលគាំទ្រដល់តំបន់សេដ្ឋកិច្ចពិសេសនិងការអភិវឌ្ឍឧស្សាហកម្ម
- រៀបចំ កំណត់ទីតាំង និងកសាងកំពង់ផែទេសចរណ៍និងអ្នកដំណើរអន្តរជាតិ និងកំពង់ផែទេសចរណ៍និងអ្នកដំណើរក្នុងស្រុក តាមការកំណត់របស់គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំប្រព័ន្ធដឹកជញ្ជូននិងមធ្យោបាយដឹកជញ្ជូនស្របតាមតម្រូវការ។

### ៤.៤.៦- ផ្លូវអាកាស

- ពង្រីកបន្ថែម និងអភិវឌ្ឍអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ ស្របតាមតម្រូវការកំណើនសេដ្ឋកិច្ចនិងភ្ញៀវទេសចរណ៍។

### ៤.៤.៧- រ៉ែ ប្រេងកាត ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា

- ជំរុញស្តារ និងអភិវឌ្ឍវិស័យរ៉ែ ប្រេងកាត ថាមពល អគ្គិសនី ទូរគមនាគមន៍ និងប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគាំទ្រដល់ការអភិវឌ្ឍឧស្សាហកម្ម ទេសចរណ៍ សេដ្ឋកិច្ច និងពាណិជ្ជកម្ម។

៤.៤.៨- សមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធ

- ធ្វើសមាហរណកម្មហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច សង្គម វប្បធម៌ បច្ចេកទេស និងសេវាកម្ម
- រៀបចំសមាហរណកម្មប្រព័ន្ធដឹកជញ្ជូន និងមធ្យោបាយដឹកជញ្ជូនផ្លូវគោក ផ្លូវសមុទ្រ និងផ្លូវអាកាស ដោយផ្តោតការយកចិត្តទុកដាក់ទាំងក្របខណ្ឌជាតិ ក្របខណ្ឌតំបន់ និងក្របខណ្ឌអន្តរជាតិ មាន ជាអាទិ៍ ក្របខណ្ឌអាស៊ាន ក្របខណ្ឌមហាអនុតំបន់ទន្លេមេគង្គ ក្របខណ្ឌវិថីមួយខ្សែក្រវ៉ាត់មួយ
- រៀបចំយន្តការនិងគោលការណ៍សម្របសម្រួលនិងគ្រប់គ្រងសមាហរណកម្ម។

## ៤.៥- យុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត

### ៤.៥.១- ការផ្គត់ផ្គង់ទឹកស្អាតនៅក្រុង និងទីប្រជុំជន

ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតត្រូវបានបង្កើតឡើងក្នុងទីក្រុងនៃខេត្តព្រះសីហនុ។ ប្រព័ន្ធដែលមានស្រាប់ ត្រូវសាងសង់ជាថ្មីនិងពង្រីកដើម្បីរក្សាតុល្យភាពជាមួយកំណើនប្រជាជន។ តម្រូវការបន្ទាន់បំផុតសម្រាប់ការកែលម្អនៃការផ្គត់ផ្គង់ទឹកស្អាតក្នុងតំបន់ទីក្រុងគឺមានតាមលំដាប់អាទិភាពដូចខាងក្រោម៖

- សិក្សាពីជលសាស្ត្រនិងត្រួតពិនិត្យតាមដាន ដើម្បីធានានូវបរិមាណទឹកស្អាតនៃធនធានទឹកដែល អាចមាន
- សិក្សា កំណត់ និងការពារទីតាំងប្រភពទឹកស្អាត ដើម្បីធានាការផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្ត រួមមាន អាងស្តុកទឹកតំបន់ប្រើប្រាស់ច្រើនយ៉ាងក្បាលឆាយ អាងស្តុកទឹកថ្មដារ អាងស្តុកទឹកឃុំព្រៃនប់ អាងស្តុកទឹកឃុំសំរុងនិងឃុំអណ្តូងថ្ម អាងស្តុកទឹកចង្កេះភ្នំបូកគោ តាមផ្លូវជាតិលេខ៣ ភូមិព្រៃក ផ្គាវ ភូមិទួល ឃុំទឹកល្អក់ និងភូមិកំពង់ចិន ភូមិព្រៃកទាល់ ឃុំទឹកថ្លា អាងស្តុកទឹកឃុំទំនប់រលក អាងស្តុកទឹកទំនប់បង្ងៀរសម្តេច ហ៊ុន សែន ឃុំអូរត្រេះ អាងស្តុកទឹករោងចក្រប្រេងកាត ឃុំអូរ ត្រេះ អាងស្តុកទឹកឃុំកែវផុស ប្រភពទឹកស្អាតស្ទឹងអ៊ី ចំណុចគីឡូម៉ែត្រលេខ១១ ភូមិក្រាំងអាត់ ឃុំ កំពង់សិលា
- រៀបចំបទប្បញ្ញត្តិ និងចាត់វិធានការការពារប្រភពផ្គត់ផ្គង់ទឹកស្អាត
- ស្តារឡើងវិញនិងដោះដូរបំពង់ទឹកចាស់ៗដើម្បីកាត់បន្ថយការលេចនិងបង្កើតគុណភាពទឹក
- ពង្រីកបណ្តាញចែកចាយទឹកដើម្បីបម្រើសេចក្តីត្រូវការរបស់ប្រជាជនឱ្យបានច្រើនជាងមុន និងដើម្បី បង្កើនប្រាក់ចំណូល
- ការពារ ពង្រីកបន្ថែម សាងសង់អាងស្តុកទឹក និងបណ្តាញបែងចែកទឹក ដើម្បីធានាការផ្គត់ផ្គង់ស្រប តាមការរីកចម្រើននិងការប្រើប្រាស់
- បន្តពង្រឹងសមត្ថភាពនិងគ្រប់គ្រងដំណើរការថែទាំ ជួសជុល និងការពារបណ្តាញចែកចាយទឹកឱ្យ ស្របតាមបទដ្ឋានបច្ចេកទេស។

### ៤.៥.២- ការផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ

- ការពារប្រភពទឹកលើដីដែលមានស្រាប់ ដើម្បីអភិវឌ្ឍនិងប្រើប្រាស់ជាទឹកស្អាត
- អភិវឌ្ឍនិងពង្រីកបន្ថែមអាងស្តុកទឹកដើម្បីផ្គត់ផ្គង់ទឹកស្អាតនៅតំបន់ជនបទ។

## ៤.៦- យុទ្ធសាស្ត្រការពារបរិស្ថាននិងធនធានធម្មជាតិ

### ៤.៦.១- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រឹង

- បង្កើតយន្តការនិងហេដ្ឋារចនាសម្ព័ន្ធក្នុងការគ្រប់គ្រងសំណល់រឹងខេត្តព្រះសីហនុ
- រៀបចំមធ្យោបាយប្រមូលសំណល់រឹងនិងរៀបចំទីតាំងសម្រាប់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេសនិងស្តង់ដារទីក្រុងស្អាត
- អភិវឌ្ឍបច្ចេកវិទ្យាទំនើបក្នុងការគ្រប់គ្រងសំណល់រឹង
- ជំរុញឱ្យមានការអនុវត្តគោលការណ៍ ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ លើការគ្រប់គ្រងសំណល់រឹង
- ជំរុញការចូលរួមរបស់ប្រជាពលរដ្ឋនិងការវិនិយោគរបស់វិស័យឯកជននិងសាធារណៈ
- អភិវឌ្ឍទីលានចាក់សំរាមថ្មីដោយប្រើបច្ចេកវិទ្យានិងប្រព័ន្ធដំណើរការ ដើម្បីធានាបាននូវ អនាម័យល្អ ដែលមានទីតាំងស្ថិតនៅ ភូមិអូរតាសេក ឃុំអូរឧកញ៉ាហេង ស្រុកព្រៃនប់ ចម្ងាយ ២គីឡូម៉ែត្រខាងជើងផ្លូវជាតិលេខ៤។

### ៤.៦.២- យុទ្ធសាស្ត្រគ្រប់គ្រងសំណល់រាវ

- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀងនិងលូទឹកកខ្វក់ឱ្យដាច់ពីគ្នា ដោយតភ្ជាប់ទៅនឹងស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រនិងត្រូវធ្វើចម្រោះទឹកកខ្វក់ឱ្យបានស្អាតស្របតាមបទដ្ឋានបច្ចេកទេសអនាម័យ មុននឹងបង្ហូរចេញទៅលូសាធារណៈ
- ណែនាំគ្រប់ម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈ ត្រូវមានអាងប្រព្រឹត្តកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ផ្សព្វផ្សាយពីគោលការណ៍បរិស្ថានអនាម័យ ដើម្បីធានាបានតំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុជាឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក។

### ៤.៦.៣- ការបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន

កំណត់ និងបែងចែកតំបន់ប្រើប្រាស់ដីសម្រាប់ការការពារបរិស្ថាន ស្របតាមច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដូចខាងក្រោម៖

- តំបន់ស្នូល
- តំបន់អភិរក្ស
- តំបន់ប្រើប្រាស់ច្រើនយ៉ាងប្រកបដោយចីរភាព
- តំបន់សហគមន៍។

### ៤.៦.៤- វិធានការចាំបាច់ក្នុងការការពារតំបន់សំខាន់ៗ

- ការពារនិងថែរក្សាឧទ្យានជាតិព្រះសីហនុរាម ភ្នំ ធនធានធម្មជាតិ ព្រៃឈើ នៅតាមកោះ សមុទ្រ ដៃសមុទ្រ ព្រែក បឹង ស្ទឹង អូរ និងប្រព័ន្ធបណ្តាញផ្លូវទឹក ស្របតាមបទប្បញ្ញត្តិជាធរមាន
- ការពារនិងថែរក្សាព្រៃកោងកាង ដើម្បីធានាប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាងមានផលិតភាពខ្ពស់និងមានសារៈសំខាន់នៅក្នុងអាយុកាលនៃសារពាង្គកាយក្នុងសមុទ្រ ដូចជាមានតួនាទី សំខាន់ជាកន្លែងពងកូនឬកន្លែងរកចំណីសម្រាប់ធនធានវារិជាតនិងប្រភេទត្រីសមុទ្រ
- ការពារនិងថែរក្សាព្រៃតំបន់ប្រើប្រាស់ច្រើនយ៉ាងព្រែកទឹកសាបក្បាលឆាយនិងព្រៃក្នុងតំបន់ទីជម្រាលដើម្បីធានាការគ្រប់គ្រងបរិស្ថាន ប្រកបដោយចីរភាព។

### ៤.៧- យុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម

- កំណត់ និងរៀបចំសំណង់សម្រាប់ផ្តល់សេវាជូនសាធារណជនរួមមាន៖
    - អគាររដ្ឋបាលសាធារណៈ អគារសិក្សាសាធារណៈ មន្ទីរពេទ្យសាធារណៈ
    - ចំណតយានយន្តសាធារណៈ ចំណតរថយន្តក្រុង ចំណតរថយន្តឈ្នួល ស្ថានីយរថភ្លើងសម្រាប់អ្នកដំណើរ ស្ថានីយចែកចាយទំនិញ ផែស្ងួត មជ្ឈមណ្ឌលផ្គត់ផ្គង់ភស្តុភារកម្ម។ល។ ត្រូវរៀបចំសម្រាប់មនុស្សទូទៅនិងជនពិការ និងមិនត្រូវស្ថិតនៅលើចិញ្ចើមផ្លូវសាធារណៈសម្រាប់ថ្មើរជើងឡើយ។
- ជំរុញ និងលើកស្ទួយការអប់រំប្រកបដោយប្រសិទ្ធភាពនិងមានសមធម៌ ដែលក្នុងនោះត្រូវ៖
    - រៀបចំឱ្យមានសាលាមត្តេយ្យសិក្សា ដែលត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់ ៥០០ (ប្រាំរយ)ម៉ែត្រ ឬភូមិមួយត្រូវមានសាលាមត្តេយ្យសិក្សាមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង
    - រៀបចំឱ្យមានសាលាបឋមសិក្សាដែលត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់ ៥០០ (ប្រាំរយ)ម៉ែត្រ ឬភូមិមួយត្រូវមានសាលាបឋមសិក្សាមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង
    - រៀបចំឱ្យមានអនុវិទ្យាល័យដែលត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់ ៣ ០០០ (បីពាន់) ម៉ែត្រ ឬឃុំមួយត្រូវមានអនុវិទ្យាល័យមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង
    - រៀបចំឱ្យមានវិទ្យាល័យដែលត្រូវមានចម្ងាយយ៉ាងច្រើនត្រឹមកាំរង្វង់ ៥ ០០០(ប្រាំពាន់)ម៉ែត្រ ឬស្រុកមួយត្រូវមានវិទ្យាល័យមួយយ៉ាងតិច ឬស្របតាមបទដ្ឋានបច្ចេកទេសនិងស្ថានភាពភូមិសាស្ត្រនៃទីតាំងជាក់ស្តែង
    - រៀបចំ និងកសាងសកលវិទ្យាល័យរដ្ឋ និងជំរុញការអភិវឌ្ឍសកលវិទ្យាល័យឯកជន នៅខេត្តព្រះសីហនុ

- រៀបចំ និងកសាងវិទ្យាស្ថានជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា នៅខេត្តព្រះសីហនុ។

– រៀបចំលំហសាធារណៈនិងផ្ទៃបៃតងក្នុងប្រភេទដីអាចសាងសង់បាន មានទំហំយ៉ាងតិច ៥ (ប្រាំ) ភាគរយនៃផ្ទៃដីសរុបក្នុងប្រភេទដីអាចសាងសង់បាន។ លំហសាធារណៈ ត្រូវរៀបចំឱ្យមានហេដ្ឋារចនាសម្ព័ន្ធសម្រាប់មនុស្សទូទៅនិងជនពិការ

– ជំរុញ និងរៀបចំលំហសាធារណៈនិងផ្ទៃបៃតងសម្រាប់សាធារណជន ដែលក្នុងនោះត្រូវ៖

- រៀបចំឱ្យមានសួនកុមារសម្រាប់វ័យមត្តេយ្យសិក្សា និងបឋមសិក្សាលេងនិងហាត់កីឡាបំពាក់ដោយឧបករណ៍និងសម្ភារៈដែលមានសុវត្ថិភាព និងជួយដល់ការរីកចម្រើននៃការវិវត្តរបស់កុមារ ចំពោះភាពឆ្លាតវៃនិងសុខភាពល្អ
- រៀបចំឱ្យមានសួនសាធារណៈភូមិសម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងសហគមន៍ ឬតំបន់លំនៅឋាននីមួយៗដែលអាចប្រើប្រាស់ដោយផ្ទាល់និងមិនផ្ទាល់
- រៀបចំឱ្យមានសួនសាធារណៈសង្កាត់សម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងសង្កាត់ និងតំបន់ជិតខាងនូវសកម្មភាពសម្រាកកម្សាន្ត លំហែ និងកីឡា
- រៀបចំឱ្យមានសួនសាធារណៈទីក្រុងសម្រាប់បម្រើដល់ប្រជាពលរដ្ឋក្នុងទីក្រុងនូវសកម្មភាពសម្រាកកម្សាន្ត លំហែ និងកីឡា
- រៀបចំឱ្យមានសួនតំបន់ជាសួនខ្នាតធំ ដែលប្រើប្រាស់សម្រាប់តំបន់ឬទីក្រុងច្រើនក្នុងគោលបំណងថែរក្សា ទេសភាព និងសោភណភាពធម្មជាតិ ដែលប្រើប្រាស់សម្រាប់ការធ្វើដំណើរ និងការបោះជំរុំទេសចរណ៍ និងកម្សាន្ត របស់ប្រជាពលរដ្ឋក្នុងទីក្រុង
- រៀបចំឱ្យមានឧទ្យានរុក្ខសាស្ត្ររៀបចំដាំដុះរុក្ខជាតិដ៏សំបូរបែប ក្នុងគោលបំណងការសិក្សាស្រាវជ្រាវ ការកម្សាន្ត និងការទស្សនា។ ឧទ្យាននេះត្រូវបានប្រជាពលរដ្ឋចូលចិត្តធ្វើដំណើរទេសចរណ៍ និងកម្សាន្តជាលក្ខណៈគ្រួសារ ហើយចំណាយពេលវេលាស្ទើរពេញមួយថ្ងៃ
- រៀបចំឱ្យមានសួនសត្វរៀបចំចិញ្ចឹមសត្វព្រៃដ៏សំបូរបែប ក្នុងគោលបំណងការសិក្សាស្រាវជ្រាវ ការកម្សាន្ត និងការទស្សនា
- រៀបចំឱ្យមានសួនសាធារណៈតាមដងផ្លូវ បណ្តាញបៃតងដែលរៀបចំដាំដើមឈើលើសួនសាធារណៈនិងតាមដងផ្លូវដើម្បីតភ្ជាប់បណ្តាញបៃតងនៅក្នុងទីក្រុង។ ទំហំបណ្តាញបៃតងនេះអាស្រ័យតាមភូមិសាស្ត្រជាក់ស្តែង។

– គិតគូរពីតម្រូវការលំនៅឋានចំពោះមុខ និងការបម្រុងទុកនូវទីតាំងសម្រាប់សាងសង់លំនៅឋានសាធារណៈ និងលំនៅឋានមានតម្លៃសមរម្យ សម្រាប់គ្រួសារដែលមានប្រាក់ចំណូលមធ្យម ប្រាក់ចំណូលទាប និងក្រុមជនងាយរងគ្រោះ

– ពង្រឹងសុវត្ថិភាពកាន់កាប់ដីធ្លី តាមរយៈការកំណត់តំបន់ទីតាំងសំណង់បណ្តោះអាសន្ននៅលើដីរបស់រដ្ឋដែលត្រូវបានទន្ទ្រានកាន់កាប់ដោយខុសច្បាប់នៅក្នុងខេត្ត និងតម្រង់ទិសរកដំណោះស្រាយសម

ស្របសម្រាប់ប្រជាជនរស់នៅក្នុងសំណង់បណ្ដោះអាសន្ន និងមិនរៀបរយទាំងនោះ ដើម្បីទទួលបានលំនៅឋានសមស្រប មានសុវត្ថិភាព និងមានផាសុខភាពសម្រាប់ការស្នាក់នៅ និង/ឬប្រកបរបរចិញ្ចឹមជីវិត

- ជំរុញដោះស្រាយវិវាទដីធ្លី និងវិវាទនៃការប្រើប្រាស់ដី ស្របតាមយន្តការ និងបទដ្ឋានគតិយុត្តជាធរមាន
- លើកកម្ពស់សន្តិសុខស្បៀង ដោយការពារផ្ទៃដីកសិកម្ម ថែរក្សា ការពារ និងពង្រីកទំនប់ការពារទឹកប្រៃ ប៉ុលខែរ នៅស្រុកព្រៃនប់ និងស្ដារ ការពារ និងកសាងទំនប់ការពារទឹកប្រៃសម័យបុរាណចាប់ពីស្ពានកំពង់ស្មាច់ដល់ស្ពានត្រពាំងរពៅ ឃុំសាមគ្គី ឃុំទឹកល្អក់ និងឃុំទឹកថ្លា ក្នុងស្រុកព្រៃនប់
- សិក្សា កំណត់ និងការពារទីតាំងអាងទឹកអូរចំណារ ដើម្បីផ្គត់ផ្គង់ទឹកសម្រាប់កសិកម្ម។

## ៥- ផែនការសកម្មភាព

### ៥.១- ការអភិវឌ្ឍដែនដី និងនគរូបនីយកម្ម

- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលក្រុង ស្រុក ឃុំ សង្កាត់ ស្របតាមគោលការណ៍ណែនាំរបស់ក្រសួងមហាផ្ទៃ
- រៀបចំគម្រោងលើកកម្ពស់ និងជំរុញប៉ូលអភិវឌ្ឍជាតិតំបន់ឆ្នេរសមុទ្រទិសនិរតីនៃព្រះរាជាណាចក្រកម្ពុជាតាមរយៈការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង
- កំណត់ទីតាំងតំបន់ស្នូលសម្រាប់ការអភិវឌ្ឍ តំបន់សេដ្ឋកិច្ចពិសេស តំបន់ទេសចរណ៍ តំបន់ឧស្សាហកម្ម តំបន់ទីប្រជុំជនអាទិភាពសម្រាប់ការស្នាក់នៅ តំបន់អាកាសយានដ្ឋានអន្តរជាតិ តំបន់ភស្តុភារកម្ម និងកំពង់ផែស្វយ័តអន្តរជាតិ
- រៀបចំផែនការអភិវឌ្ឍន៍សម្រាប់អ័ក្សនៃការអភិវឌ្ឍរវាងរាជធានីភ្នំពេញ-ខេត្តព្រះសីហនុ អ័ក្សនៃការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងច្រកចេញចូលអន្តរជាតិតាមអ័ក្សនៃការអភិវឌ្ឍផ្លូវសមុទ្រ
- រៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីសម្រាប់ក្រុងព្រះសីហនុ ស្រុកស្ទឹងហាវ ស្រុកព្រៃនប់ ស្រុកកំពង់សិលា ប្លង់លំអិតនគរូបនីយកម្ម ប្លង់តំបន់ការពារទេសភាពពិសេស និងបទដ្ឋានបច្ចេកទេស ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព តុល្យភាព និងប្រសិទ្ធភាព
- រៀបចំប្លង់គោលនិងប្លង់លម្អិតដីចំណីឆ្នេរសមុទ្រ ដែលសមុទ្រ ស្ទឹង ព្រែក បឹង ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ ដោយកំណត់ និងធ្វើអត្តសញ្ញាណកម្មឆ្នេរ សមុទ្រ ដីចំណីឆ្នេរសមុទ្រ ផ្លូវសាធារណៈតាមបណ្ដោយដីចំណីឆ្នេរសមុទ្រ តំបន់រណបតាមបណ្ដោយផ្លូវសាធារណៈ ផ្លូវសាធារណៈ ផ្លូវថ្មើរជើងនិងសួនច្បារ ឬបណ្ដាញបៃតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ
- បោះបង្គោលព្រំប្រទល់ដីចំណីឆ្នេរសមុទ្រឱ្យបានច្បាស់លាស់ ដើម្បីខណ្ឌចែកឱ្យដាច់រវាងដីរដ្ឋនិងដីឯកជន

- រៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដី និងបទដ្ឋានបច្ចេកទេស សម្រាប់ការគ្រប់គ្រងនិងអភិវឌ្ឍកោះ ប្រកបដោយចីរភាព
- ជំរុញផ្សព្វផ្សាយឯកសារគតិយុត្តពាក់ព័ន្ធការងាររៀបចំដែនដីនិងនគរូបនីយកម្ម ការងារគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ពិសេសសារាចរណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា
- រៀបចំច្បាប់ស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំអនុក្រឹត្យស្តីពីការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំអនុក្រឹត្យស្តីពីការបង្កើតមូលនិធិអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជា
- រៀបចំបទដ្ឋានគតិយុត្តស្តីពីការអភិវឌ្ឍតំបន់ទេសចរណ៍ពិសេសក្នុងតំបន់ឆ្នេរកោះ។

## ៥.២- ផែនការសកម្មភាពតាមវិស័យ

- ជំរុញនិងលើកទឹកចិត្តដល់ការវិនិយោគនៅតំបន់ឆ្នេរសមុទ្រខេត្តព្រះសីហនុ ដែលមានកំពង់ផែសមុទ្រទឹកជ្រៅសំខាន់សម្រាប់ប្រទេសកម្ពុជានិងមានសក្តានុពលដ៏ធំធេងសម្រាប់ការអភិវឌ្ឍនគរូបនីយកម្ម ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្ម និងទេសចរណ៍
- កែលម្អផ្លូវជាតិលេខ៣ឱ្យមានសមត្ថភាពសមស្រប ដើម្បីបង្កើតអ័ក្សតភ្ជាប់រវាងក្រុងព្រះសីហនុ និងក្រុងកំពត
- សាងសង់ផ្លូវល្បឿនលឿនមួយបន្ថែមទៀតដែលអាចទ្រទ្រង់បាននូវការដឹកជញ្ជូនកម្រិតធ្ងន់ៗនិងធានាសុវត្ថិភាពខ្ពស់
- អភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេសឱ្យក្លាយជាឧបករណ៍មួយដ៏សំខាន់សម្រាប់ប្រទេសកម្ពុជា ក្នុងការធ្វើពាណិជ្ជកម្ម និងឧស្សាហកម្មនាំចេញ
- ពង្រឹងរដ្ឋបាលគ្រប់គ្រងតំបន់សេដ្ឋកិច្ចពិសេសឱ្យមានអភិបាលកិច្ចល្អនិងតម្លាភាព ក្នុងការគ្រប់គ្រងនិងប្រតិបត្តិការ ព្រមទាំងការពង្រឹងការអនុវត្តច្បាប់
- កែលម្អស្តង់ដារបច្ចេកទេសនិងបរិស្ថាននៃតំបន់សេដ្ឋកិច្ចពិសេស ដូចជាការបំពុលខ្យល់និងគុណភាពនៃការបង្ហូរសំណល់រាវជាដើម ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព និងចៀសវាងនូវការប៉ះពាល់ជាអវិជ្ជមានដល់បរិស្ថាននិងធនធានធម្មជាតិដែលនៅជុំវិញតំបន់សេដ្ឋកិច្ចពិសេស
- ផ្សារភ្ជាប់ទំនាក់ទំនងជាមួយអ្នកផ្គត់ផ្គង់ទំនិញនិងសេវាកម្ម ដោយផ្តោតជាសំខាន់លើការគាំទ្រដល់សហគ្រាសធុនតូចនិងមធ្យម តាមរយៈការបណ្តុះបណ្តាលធនធានមនុស្សនិងការផ្តល់មីក្រូហិរញ្ញសម្បទាន
- ពង្រឹងការអនុវត្តច្បាប់និងបទប្បញ្ញត្តិជាធរមានពាក់ព័ន្ធនឹងការវាយតម្លៃផលប៉ះពាល់បរិស្ថាន និងការសាងសង់នៃគម្រោងអភិវឌ្ឍនិងវិនិយោគនានា

- ជំរុញលើកកម្ពស់អនុវត្តផែនការសកម្មភាពនៃយុទ្ធសាស្ត្រវិស័យឧស្សាហកម្ម ទេសចរណ៍ ហេដ្ឋារចនាសម្ព័ន្ធបច្ចេកទេសនិងសេវាកម្ម ហេដ្ឋារចនាសម្ព័ន្ធសង្គមនិងវប្បធម៌ បរិស្ថាន ធនធានធម្មជាតិ ព្រៃឈើ កសិកម្ម ផលផល រ៉ែ ប្រេងកាត ថាមពល អប់រំ សុខាភិបាល ទូរគមនាគមន៍ បច្ចេកវិទ្យានិងព័ត៌មានវិទ្យា
- ផែនការសម្របសម្រួលនិងសមាហរណកម្មតាមវិស័យ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព
- រៀបចំច្បាប់ បទបញ្ញា និងសេចក្តីណែនាំបន្ថែមចាំបាច់ ដើម្បីធានាការអភិវឌ្ឍប្រកបដោយសុខដុមនីយកម្ម ប្រសិទ្ធភាពនិងចីរភាព
- អនុវត្តផែនការសកម្មភាព ដូចមានចែងក្នុងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ ២០១៥-២០២៥។

## ៥.៣- គម្រោងអាទិភាព

### ៥.៣.១- ការរៀបចំដែនដី និងនគរូបនីយកម្ម

*ក. ប្លង់គោលប្រើប្រាស់ដី*

- កំណត់ប្រភេទប្រើប្រាស់ដី ទីតាំងតំបន់នគរូបនីយកម្ម តំបន់ឧទ្យានជាតិ តំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ការពារធនធានទឹក តំបន់ការពារនិងអភិរក្ស តំបន់រមណីយដ្ឋានទេសចរណ៍ តំបន់អាទិភាពសម្រាប់ការស្នាក់នៅ។ល។
- កសាងប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លំអិតនគរូបនីយកម្មថ្នាក់ក្រុង ស្រុក ទីប្រជុំជន ឃុំ សង្កាត់ ដោយកំណត់ពីការបែងចែកតំបន់ប្រើប្រាស់ដី កម្ពស់អគារ សន្ទស្សន៍ប្រើប្រាស់ដី ផលធៀបក្រឡាផ្ទៃបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍ សួនជ្រាបទឹក និងចំណតរថយន្ត
- កំណត់កម្ពស់អគារនៅតំបន់ជុំវិញអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុ
- បណ្តុះបណ្តាលនិងពង្រឹងសមត្ថភាពធនធានមនុស្សថ្នាក់ក្រោមជាតិលើការងាររៀបចំដែនដី និងនគរូបនីយកម្ម
- រៀបចំនិងពង្រឹងការអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន។

***ខ. ផែនការប្រើប្រាស់ដីតំបន់ឆ្នេរសមុទ្រ និងកោះ***

- រៀបចំប្លង់គោលនិងប្លង់លម្អិតដីចំណីឆ្នេរសមុទ្រ ដែលសមុទ្រ ស្ទឹង ព្រែក បឹង ផ្លូវទឹកដែលតភ្ជាប់ទៅនឹងសមុទ្រ និងផ្ទៃទឹកដែលជាប់នឹងឆ្នេរសមុទ្រ ដោយកំណត់ និងធ្វើអត្តសញ្ញាណកម្មឆ្នេរ សមុទ្រ ដីចំណីឆ្នេរសមុទ្រ ផ្លូវសាធារណៈតាមបណ្តោយដីចំណីឆ្នេរសមុទ្រ តំបន់រណបតាមបណ្តោយផ្លូវសាធារណៈ ផ្លូវសាធារណៈ ផ្លូវថ្មើរជើងនិងសួនច្បារ ឬបណ្តាញបែតងក្នុងទិសឆ្ពោះទៅមាត់សមុទ្រ
- ថែរក្សា ការពារ កែលម្អ និងអភិវឌ្ឍឆ្នេរសមុទ្រ ដីចំណីឆ្នេរសមុទ្រ ផ្លូវស្របតាមបណ្តោយឆ្នេរសមុទ្រឱ្យមានអនាម័យ សោភណភាព និងគុណភាពបរិស្ថានល្អ សម្រាប់មនុស្សទាំងអស់គ្នា និងសម្រាប់ជា

ប្រយោជន៍សាធារណៈ ស្របតាមចក្ខុវិស័យជារមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកដែលកំណត់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។ ដើម្បីសម្រេចការងារនេះ ម្ចាស់ដី ឬម្ចាស់អចលនទ្រព្យដែលនៅតាមបណ្តោយឆ្នេរសមុទ្រ មានកាតព្វកិច្ចចូលរួមក្នុងការថែរក្សា ការពារអនាម័យ និងអភិវឌ្ឍកែលម្អឆ្នេរសមុទ្រដែលបន្ទុកចំណាយទាំងការអភិវឌ្ឍ និងការរៀបចំឆ្នេរសមុទ្រ សួនច្បារតាមបណ្តោយឆ្នេរសមុទ្រ ផ្លូវស្របតាមបណ្តោយឆ្នេរសមុទ្រ និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រផ្សេងៗទៀត

- រៀបចំបទដ្ឋានរមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោកដែលត្រូវកំណត់ដាក់ឱ្យប្រើប្រាស់ដោយគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា
- ការពារដីចំណីឆ្នេរសមុទ្រ ដោយកំណត់និងបោះបង្គោលព្រំប្រទល់ដីចំណីឆ្នេរសមុទ្រ ព្រែក ស្ទឹង អូរ បឹង និងបណ្តាញផ្លូវទឹកដែលភ្ជាប់ទៅនឹងសមុទ្រ
- រៀបចំប្លង់គោល ផែនការប្រើប្រាស់ដី បទដ្ឋានបច្ចេកទេស និងកំណត់ពីការបែងចែកតំបន់ប្រើប្រាស់ដីនៅលើកោះ
- រៀបចំបទដ្ឋានបច្ចេកទេសអភិវឌ្ឍន៍តំបន់ឆ្នេរសមុទ្រ និងបទដ្ឋានបច្ចេកទេសអភិវឌ្ឍន៍កោះដែលត្រូវសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងជាប្រធានគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ
- រៀបចំនិងពង្រឹងការអនុវត្តច្បាប់ បទប្បញ្ញត្តិ និងក្របខណ្ឌគតិយុត្តជាធរមាន។

### ៥.៣.២- ការលើកកម្ពស់វិស័យឧស្សាហកម្មនិងភស្តុភារកម្ម

#### *ក- វិស័យឧស្សាហកម្ម*

- កំណត់តំបន់អភិវឌ្ឍវិស័យឧស្សាហកម្ម តាមបែបបច្ចេកវិទ្យាទំនើបទិសដៅសម្រាប់នាំចេញនិងតំបន់សេដ្ឋកិច្ចពិសេស
- រៀបចំប្លង់គោលប្រើប្រាស់ដីស្រុកស្ទឹងហាវ ស្របតាមទស្សនទានជាទីក្រុងឧស្សាហកម្មបៃតងអាស៊ាន

#### *ខ- ភស្តុភារកម្ម*

- សិក្សាផែនការអភិវឌ្ឍវិស័យដឹកជញ្ជូន និងភស្តុភារកម្មគ្រប់ជ្រុងជ្រោយរវាងខេត្តព្រះសីហនុនិងរាជធានីភ្នំពេញ
- រៀបចំប្រព័ន្ធត្រួតពិនិត្យឱ្យមានលក្ខណៈអន្តរជាតិ ប្រកបដោយប្រសិទ្ធភាព
- រៀបចំនិងអង្កេតទីផ្សារ ផ្សព្វផ្សាយ អភិវឌ្ឍចំណតរថយន្ត ជំរុញការដឹកជញ្ជូនតាមផ្លូវអយស្ម័យយាន និងអភិវឌ្ឍកំពង់ផែឱ្យឆ្លើយតបនឹងតម្រូវការ។

### ៥.៣.៣- ការអភិវឌ្ឍទេសចរណ៍

- រៀបចំតំបន់ទេសចរណ៍កម្សាន្តចម្រុះបែបទីក្រុង ឆ្នេរខ្សាច់ សណ្ឋាគារ ភោជនីយដ្ឋាន កាស៊ីណូ មណ្ឌលកម្សាន្តមនុស្សពេញវ័យ

- រៀបចំតំបន់រមណីយដ្ឋានទេសចរណ៍ធម្មជាតិ អេកូទេសចរណ៍បែបស្ងប់ស្ងាត់ និងទេសចរណ៍បែបផ្សងព្រេង នៅឧទ្យានជាតិព្រះសីហនុរាម ចាប់ពីអាកាសយានដ្ឋានអន្តរជាតិខេត្តព្រះសីហនុរហូតដល់ព្រំប្រទល់ខេត្តកំពត
- កំណត់អត្តសញ្ញាណ និងតំបន់ទេសចរណ៍តាមឆ្នេរសមុទ្រ និងកោះ
- សិក្សាទីតាំងនិងប្លង់កំពង់ផែទេសចរណ៍នៅតំបន់ដីគោក និងនៅតាមកោះ។

### ៥.៣.៤- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ

*ក- បណ្តាញផ្លូវថ្នល់*

- រៀបចំនិងកែលម្អផ្លូវឧស្សាហកម្មនិងផ្លូវទេសចរណ៍ ដោយកំណត់ផ្លូវជាតិលេខ៤ និងផ្លូវសម្តេចសង្ឃទេព វង្ស និងតិរវិថីសម្តេចហ៊ុន សែន ភ្ជាប់មកកំពង់ផែស្វយ័តក្រុងព្រះសីហនុ ជាផ្លូវបម្រើដល់វិស័យឧស្សាហកម្ម និងកែលម្អស្ពានដែលមានស្រាប់ប្រមាណ២១កន្លែង
- ស្តារនិងអភិវឌ្ឍផ្លូវចំនួន៤ភ្ជាប់ពីផ្លូវជាតិលេខ៤ទៅតំបន់កណ្តាលក្រុងព្រះសីហនុ ដើម្បីសម្រួលការធ្វើដំណើរនិងទេសចរ ក្នុងនោះមាន៖ ១).ពីផ្លូវជាតិលេខ៤ត្រង់ចំណុចភូមិ១ សង្កាត់លេខ១ ក្រុងព្រះសីហនុទៅវិថីមិត្តភាពនិងវិថីឯករាជ្យ ២).ពីផ្លូវជាតិលេខ៤ត្រង់ចំណុចអូរត្រាវទៅវិថីមិត្តភាពនិងវិថីអូរឈើទាល ៣).ពីផ្លូវជាតិលេខ៤ត្រង់ចំណុចសាលាឃុំបិតត្រាំងកាត់ពយម៉ាចូវឆ្ពោះទៅវិថីស្របឆ្នេរអូរត្រេះនិងវិថីឆ្នេរអូរឈើទាល ៤).ពីផ្លូវជាតិលេខ៤ ផ្លូវជាតិលេខ៤៥ កាត់ស្របតាមបណ្តោយឆ្នេរចំការដូងចេងហេងភ្ជាប់ទៅពយម៉ាចូវ។

*ខ- បណ្តាញផ្គត់ផ្គង់ទឹកស្អាត*

- រៀបចំកន្លែងស្តុកទឹក
- បំពាក់ប្រព័ន្ធចែកចាយទឹកពីបំពង់មេ និងបំពាក់ឧបករណ៍មួយចំនួនសម្រាប់នាំទឹកដែលច្រោះរួចពីតំបន់ក្បាលឆាយ
- កែលម្អនិងរៀបចំឡើងវិញនូវប្រព័ន្ធចែកចាយ ដើម្បីធ្វើឱ្យប្រសើរឡើងនូវភាពបត់បែននិងកាត់បន្ថយសម្ពាធក្នុងផ្នែកផ្សេងៗនៃប្រព័ន្ធ។

### ៥.៣.៥- ការគ្រប់គ្រងធនធានធម្មជាតិនិងបរិស្ថាន

*ក- ការគ្រប់គ្រងសំណល់រឹងនិងរាវ*

- រៀបចំនិងពង្រីកបន្ថែមប្រព័ន្ធលូទឹកភ្លៀង លូទឹកកខ្វក់ឱ្យដាច់ពីគ្នា និងស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ស្របតាមស្ថានភាពទីតាំងភូមិសាស្ត្រ និងត្រូវធ្វើចម្រោះទឹកកខ្វក់ឱ្យបានស្អាតមុននឹងបង្ហូរចេញទៅលូសាធារណៈដើម្បីធានាចីរភាពបរិស្ថាន

- រៀបចំប្រព័ន្ធលូតភ្ជាប់ទៅនឹងស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់ សម្រាប់តំបន់ទាំងបីរួមមាន ១).តំបន់ឆ្នេរអូរឈើទាលនិងឆ្នេរអូរត្រេះ ២).តំបន់ក្រុងទិសឦសាន្ត និង ៣).តំបន់ក្រុងទៅទិសខាងលិចនៃតំបន់សេវាកម្មដែលមានស្រាប់
- ណែនាំម្ចាស់សំណង់លំនៅឋាន ឧស្សាហកម្ម ពាណិជ្ជកម្ម សេវាកម្មទេសចរណ៍ និងសំណង់សាធារណៈ ឱ្យសាងសង់អាងប្រព្រឹត្តកម្មទឹកកខ្វក់ និងអាងបង្គន់អនាម័យឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- រៀបចំ និងអភិវឌ្ឍទីលានចាក់សំណល់រឹងស្របតាមបទដ្ឋានបច្ចេកទេសបរិស្ថាន
- អនុវត្តការគ្រប់គ្រងសំណល់រឹងតាមគោលការណ៍ "ការកាត់បន្ថយ ការប្រើប្រាស់ឡើងវិញ និងការកែច្នៃ"
- ផ្សព្វផ្សាយឱ្យបានទូលំទូលាយដល់សាធារណជនអំពីវិធានការគ្រប់គ្រងសំណល់រឹងនិងរាវ។

*ខ- ការអភិរក្សធនធានធម្មជាតិ ឆ្នេរសមុទ្រ និងកោះ*

- ការពារនិងថែរក្សាធនធានធម្មជាតិនៅតាមឆ្នេរសមុទ្រ កោះ និងវាយតម្លៃឆ្នេរសមុទ្រស្អាត
- អភិរក្សធនធានធម្មជាតិ ដោយស្តារឡើងវិញនូវគម្របព្រៃឈើ ព្រៃកោងកាង និងធនធានសមុទ្រ
- ពង្រឹងសមត្ថភាពនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននិងសង្គម។

## ៦- ធនធានហិរញ្ញវត្ថុ

ប្រភពធនធានហិរញ្ញវត្ថុសម្រាប់ការអនុវត្តផែនការរៀបចំដែនដីខេត្តព្រះសីហនុ មានជាអាទិ៍៖

- ថវិកាជាតិ
- ថវិកាឯកជន
- ថវិកាភាពជាដៃគូរវាងរដ្ឋនិងឯកជន
- ថវិកាហិរញ្ញប្បទានរបស់ដៃគូអភិវឌ្ឍនិងកិច្ចសហប្រតិបត្តិការអន្តរជាតិ
- ថវិកាពីការចូលរួមរបស់ប្រជាពលរដ្ឋ សហគមន៍ និងសប្បុរសជន។

## ៧- ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

### ៧.១- យន្តការ

យន្តការថ្នាក់ជាតិដើម្បីត្រួតពិនិត្យ តាមដាន និងវាយតម្លៃការអនុវត្តផែនការរៀបចំដែនដី ការអភិវឌ្ឍខេត្តព្រះសីហនុមាន៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដី និងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា ដែលដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងក្រសួង ស្ថាប័នតាមវិស័យរបស់រដ្ឋ។

គណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា (គ.អ.ឆ.ក) ដែលដឹកនាំដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ និងមានក្រសួង ស្ថាប័នពាក់ព័ន្ធជាសមាជិក គឺជាយន្តការថ្នាក់

ជាតិសម្រាប់ធានាការគ្រប់គ្រងការអភិវឌ្ឍនិងការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជាប្រកបដោយចីរភាព សមាហរណកម្ម និងសមធម៌ ដែលមានតួនាទីនិងភារកិច្ច ដូចបានកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា និងព្រះរាជក្រឹត្យលេខ នស/រកត/០៦១៤/៦៧១ ចុះថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៤ និងមាត្រា១២នៃព្រះរាជក្រឹត្យលេខ នស/រកត/០២១២/០៧៩ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការបង្កើតគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

យន្តការថ្នាក់ក្រោមជាតិសម្រាប់អនុវត្តមាន៖ អភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ គណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ ដែលមានមន្ទីរ អង្គភាពពាក់ព័ន្ធរបស់ខេត្ត និងអាជ្ញាធរក្រុង ស្រុក ឃុំ សង្កាត់ ជាសមាជិក។

គណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ ដែលដឹកនាំដោយអភិបាលនៃគណៈអភិបាលខេត្តព្រះសីហនុនិងមានមន្ទីរ អង្គភាពពាក់ព័ន្ធជាសមាជិក គឺជាយន្តការថ្នាក់ក្រោមជាតិសម្រាប់ធានាការគ្រប់គ្រងការអភិវឌ្ឍ និងការអភិរក្សតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុប្រកបដោយចីរភាពនិងសមធម៌ ដែលមានតួនាទីនិងភារកិច្ច ដូចបានកំណត់ក្នុងសេចក្តីសម្រេចលេខ០២៤ សសរ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពគណៈកម្មាធិការគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជាខេត្តព្រះសីហនុ។

### ៧.២- ច្បាប់ គោលនយោបាយ និងលិខិតបទដ្ឋានគតិយុត្ត

ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តការរៀបចំដែនដី និងនគរូបនីយកម្ម ខេត្តព្រះសីហនុត្រូវអនុវត្តដោយផ្អែកទៅលើផែនការរៀបចំដែនដីខេត្តព្រះសីហនុ ដែលបានអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ និងច្បាប់ គោលនយោបាយ និងក្របខណ្ឌគតិយុត្ត មានជាអាទិ៍ ច្បាប់ភូមិបាល ច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់ ច្បាប់ស្តីពីកិច្ចការពារបរិស្ថាននិងធនធានធម្មជាតិ ច្បាប់ស្តីពីព្រៃឈើ ច្បាប់ស្តីពីជលផលច្បាប់ស្តីពីផ្លូវថ្នល់ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ គោលនយោបាយដីធ្លី គោលនយោបាយជាតិស្តីពីការរៀបចំដែនដី នៃព្រះរាជាណាចក្រកម្ពុជា គោលនយោបាយជាតិស្តីពីលំនៅឋាន គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ឆ្នាំ២០១៥-២០២៥ អនុក្រឹត្យស្តីពីការបង្កើតគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ អនុក្រឹត្យស្តីពីលិខិតអនុញ្ញាតសាងសង់ អនុក្រឹត្យស្តីពីនគរូបនីយកម្មរាជធានី ក្រុង និងទីប្រជុំជន អនុក្រឹត្យស្តីពីនីតិវិធីនៃការធ្វើផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ សារាចរណែនាំស្តីពីការអភិវឌ្ឍតំបន់ឆ្នេរសមុទ្រនៃព្រះរាជាណាចក្រកម្ពុជា សេចក្តីសម្រេចស្តីពីការរៀបចំប្លង់គោលនិងផែនការប្រើប្រាស់ដីថ្នាក់ក្រុង ស្រុក ខណ្ឌ ច្បាប់ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

### ៧.៣- ភារកិច្ច នីតិវិធី និងគោលការណ៍

គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មខេត្តព្រះសីហនុ ដោយមានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុជាសមាជិកអចិន្ត្រៃយ៍ មានភារកិច្ច៖

- ទទួលខុសត្រូវក្នុងការរៀបចំផែនការសកម្មភាពលម្អិត សម្រាប់ការអនុវត្តផែនការរៀបចំដែនដីនេះ ដោយមានការចូលរួមពីក្រសួង ស្ថាប័ន មន្ទីរ អង្គភាព វិស័យឯកជន ដៃគូអភិវឌ្ឍ និងសហគមន៍មូលដ្ឋាន។ ផែនការសកម្មភាពលម្អិតខាងលើត្រូវកំណត់នូវគោលបំណង គោលដៅ សកម្មភាព ពេលវេលា ធនធានហិរញ្ញវត្ថុ ការទទួលខុសត្រូវ និងសូចនាករសំខាន់ៗសម្រាប់ការត្រួតពិនិត្យនិងការវាយតម្លៃ ព្រមទាំងត្រូវមានសង្គតិភាពជាមួយផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍៥ឆ្នាំ កម្មវិធីវិនិយោគ៣ឆ្នាំរំកិល ប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងប្លង់លម្អិតនគរូបនីយកម្ម
- ត្រូវធ្វើបច្ចុប្បន្នភាពផែនការរៀបចំដែនដីខេត្តព្រះសីហនុ និងស្នើសុំការឯកភាពមកគណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ ដើម្បីស្នើសុំការសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការពីរាជរដ្ឋាភិបាល ក្នុងរយៈពេល៥ឆ្នាំម្តង ស្របតាមគោលការណ៍និងនីតិវិធីជាធរមាន
- ត្រូវធ្វើរបាយការណ៍ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ ស្តីពីការអនុវត្តផែនការរៀបចំដែនដីនេះជូនក្រសួងមហាផ្ទៃ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ និងគណៈកម្មាធិការជាតិគ្រប់គ្រងនិងអភិវឌ្ឍតំបន់ឆ្នេរសមុទ្រកម្ពុជា។

គោលការណ៍នៃការត្រួតពិនិត្យនិងវាយតម្លៃ ត្រូវផ្អែកលើសូចនាករនៃការរៀបចំដែនដីនិងនគរូបនីយកម្ម និងសូចនាករតាមវិស័យ ដែលជាកត្តាគួសបញ្ជាក់អំពីប្រសិទ្ធភាពនៃផែនការរៀបចំដែនដីក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។

## ៨- សេចក្តីសន្និដ្ឋាន

ព្រះរាជាណាចក្រកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ទទួលបាននូវសុខសន្តិភាពពេញលេញ ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ព្រមទាំងការអភិវឌ្ឍរីកចម្រើនលើគ្រប់វិស័យ តាមរយៈការអនុវត្តគោលនយោបាយឈ្នះ-ឈ្នះ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា។ ផែនការរៀបចំដែនដីខេត្តព្រះសីហនុ ត្រូវបានរៀបចំឡើងនិងអនុម័តដាក់ឱ្យប្រើប្រាស់ជាផ្លូវការ គឺជាឧបករណ៍គតិយុត្តគោល សម្រាប់ការអនុវត្តនិងសម្របសម្រួលស្ថាប័នពាក់ព័ន្ធតាមវិស័យដ៏មានសារៈសំខាន់ ដើម្បីធានាសម្រេចបានចក្ខុវិស័យដល់ឆ្នាំ២០៣០ គឺ **«ខេត្តព្រះសីហនុជាប៉ូលអភិវឌ្ឍជាតិប្រកបដោយចីរភាព នៅតំបន់ឆ្នេរសមុទ្រកម្ពុជា តាមរយៈការជំរុញការអភិវឌ្ឍទីក្រុងទំនើប រមណីយដ្ឋានឆ្នេរសមុទ្រដែលស្អាតបំផុតលើសកលលោក តំបន់សេដ្ឋកិច្ចពិសេសគំរូពហុបំណង ច្រកចេញចូលអន្តរជាតិ មជ្ឈមណ្ឌលកំណើនជាតិ មជ្ឈមណ្ឌលភស្តុភារកម្មជាតិដោយមានទំនាក់ទំនងជាមួយទីផ្សារអាស៊ាននិងទីផ្សារសកលលោក និងមជ្ឈមណ្ឌលឧស្សាហកម្មផលិតកម្មបែបបច្ចេកវិទ្យាទំនើប ដែលមានសុខុដុមនីយកម្មជាមួយនឹងបរិស្ថានរស់នៅល្អប្រសើរ»**។

ផ្អែកលើសមិទ្ធផលសម្រេចបានកន្លងមក ផ្អែកលើសក្តានុពលដ៏ធំធេងរបស់ខេត្តព្រះសីហនុ ផ្អែកលើឆន្ទៈដ៏មុះមុត និងទេពកោសល្យរបស់ប្រជាជនកម្ពុជា ព្រមទាំងផ្អែកលើសមត្ថភាពការរៀនសូត្រ ការដកស្រង់

នូវបទពិសោធន៍ ការតម្រឹម ការបន្សាំ និងការចេះជ្រើសយកវិធានការចាំបាច់របស់រាជរដ្ឋាភិបាលនិងរបស់ប្រជាជនកម្ពុជាទាំងមូល រួមជាមួយចក្ខុវិស័យ គោលបំណង គោលដៅ ក្របខណ្ឌយុទ្ធសាស្ត្រ ផែនការសកម្មភាពដ៏ត្រឹមត្រូវដែលបានដាក់ចេញមកនេះ រាជរដ្ឋាភិបាលមានជំនឿយ៉ាងមុតមាំថា ខេត្តព្រះសីហនុនឹងជំនះបាននូវរាល់បញ្ហាប្រឈមនិងឧបសគ្គ នៅលើមាគ៌ាឆ្ពោះទៅកាន់វឌ្ឍនភាព វិបុលភាព និងភាពថ្កុំថ្កើនរុងរឿង ស្របតាមគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ ២០៥០។

ដើម្បីលើកកម្ពស់ការយល់ដឹងដល់សាធារណជនផ្នែកធុរកិច្ច និងសង្គមស៊ីវិល ក្នុងការចូលរួមចំណែកអនុវត្ត តាមដាន និងវាយតម្លៃចំពោះផែនការរៀបចំដែនដីខេត្តព្រះសីហនុ ក្រសួងរៀបចំដែនដី នគរូបនីយកម្មនិងសំណង់ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ជាតិ គណៈកម្មាធិការរៀបចំដែនដីនិងនគរូបនីយកម្មថ្នាក់ខេត្ត ថ្នាក់ក្រុង និងថ្នាក់ស្រុក អាជ្ញាធរមានសមត្ថកិច្ច នឹងត្រូវជំរុញការផ្សព្វផ្សាយនិងអនុវត្តឱ្យមានប្រសិទ្ធភាពក្នុងស្មារតីទទួលខុសត្រូវខ្ពស់នូវផែនការរៀបចំដែនដីខេត្តព្រះសីហនុ ដើម្បីធានាការអភិវឌ្ឍប្រកបដោយចីរភាព ហើយត្រូវរាយការណ៍ពីលទ្ធផលនៃការអនុវត្តជូនរាជរដ្ឋាភិបាល៕

## សន្ទានុក្រម

**ទីក្រុង** សំដៅដល់រាជធានី ក្រុង និងទីប្រជុំជន។ ទីក្រុងត្រូវបានធ្វើចំណាត់ថ្នាក់ជាទីក្រុងប្រភេទធំ ប្រភេទមធ្យម និងប្រភេទតូច ស្របតាមលក្ខខណ្ឌនៃចំនួនប្រជាជន ដង់ស៊ីតេប្រជាជន សមាមាត្រអ្នកធ្វើការមិនមែនជាកសិករ មុខងារទីក្រុង និងរចនាសម្ព័ន្ធរូបវន្តទីក្រុង។ល។

**នគរូបនីយកម្ម** សំដៅដល់សិល្បៈវិទ្យាសាស្ត្រ និងបច្ចេកទេសនៃការធ្វើផែនការរូបវន្តទីក្រុង ការអភិវឌ្ឍ ការអភិរក្ស ការគ្រប់គ្រងការអភិវឌ្ឍ ការសាងសង់ និងការកែលម្អនៅក្នុងទីក្រុងនិងតំបន់ជុំវិញ ព្រមទាំង តំបន់ទទួលឥទ្ធិពល ក្នុងគោលបំណងទទួលបាននូវចីរភាព តុល្យភាព សុខុមាលភាព សោភណភាព សមធម៌ និងសមាហរណកម្ម។

**ផែនការរៀបចំដែនដីថ្នាក់ជាតិ តាមតំបន់ ថ្នាក់ខេត្ត** ជាផែនការដែលកំណត់ចក្ខុវិស័យនិងយុទ្ធសាស្ត្រតម្រង់ទិសការប្រើប្រាស់ដី និងការអភិវឌ្ឍផ្នែករូបវន្ត ដោយផ្អែកលើសក្កានុពលនៃភូមិសាស្ត្រ និងតំបន់នីមួយៗ ក្នុងក្របខណ្ឌថ្នាក់ជាតិ តាមតំបន់ និងថ្នាក់ខេត្ត។

**ប្លង់គោលប្រើប្រាស់ដីឬប្លង់គោល** សំដៅដល់ផែនការដែលកំណត់អំពីចក្ខុវិស័យនិងយុទ្ធសាស្ត្រសរុប សម្រាប់ការអភិវឌ្ឍរូបវន្តនិងកំណត់ពីប្រភេទនៃការប្រើប្រាស់ដី (ប្រភេទដីអាចសាងសង់បាននិងប្រភេទដីកម្រិតការសាងសង់) ព្រមទាំងបង្ហាញអំពីទម្រង់ទីក្រុង បណ្ដាញហេដ្ឋារចនាសម្ព័ន្ធទីក្រុង និងគមនាគមន៍សំខាន់ៗនៃទីក្រុងព្រមទាំងការធ្វើសមាហរណកម្ម។ ប្លង់គោលប្រើប្រាស់ដីត្រូវភ្ជាប់មកជាមួយនូវផែនការសកម្មភាពសម្រាប់អភិវឌ្ឍនិងអភិរក្សទីក្រុង ទៅតាមលំដាប់អាទិភាពសម្រាប់រយៈពេលខ្លី រយៈពេលមធ្យម និងរយៈពេលវែង។ ប្លង់គោលប្រើប្រាស់ដីគឺជាប្លង់ដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ផែនការប្រើប្រាស់ដី** សំដៅដល់ផែនការលម្អិតចេញពីប្លង់គោលប្រើប្រាស់ដីដែលកំណត់អំពីប្រភេទប្រើប្រាស់ដី តំបន់ប្រើប្រាស់ដី និងកំណត់អំពីបទបញ្ញានៃការប្រើប្រាស់ដីជាក់ស្ដែង ការសាងសង់ ការអភិវឌ្ឍដីនិងរយៈពេលការអភិរក្សក្នុងតំបន់នីមួយៗ ព្រមទាំងកំណត់អំពីបណ្ដាញគមនាគមន៍ និងការធ្វើសមាហរណកម្ម។ ផែនការប្រើប្រាស់ដីគឺជាផែនការដែលត្រូវបានសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយស្ថាប័នរដ្ឋមានសមត្ថកិច្ច។

**ប្លង់លម្អិតនគរូបនីយកម្ម** សំដៅដល់ប្លង់វិលេចទីតាំងនៃតំបន់ណាមួយក្នុងទីក្រុង ឬជាគម្រោងអភិវឌ្ឍទីក្រុង ដើម្បីបង្ហាញអំពីយុទ្ធសាស្ត្ររូបបន្តលម្អិតនៃការរៀបចំផ្នែក ទីតាំង ឬតំបន់ប្រើប្រាស់ដីណាមួយ ឬច្រើនទីក្រុង ដែលរួមមានការបង្ហាញអំពីការរៀបចំការរចនាទម្រង់ រូបរាង និងសោភណភាពនៃរចនាសម្ព័ន្ធរូបវន្ត សម្រាប់ការអភិវឌ្ឍ ការអភិរក្សនិងការសាងសង់ តាមរយៈគំនូរ ឬរូបសំណាក។ ប្លង់លម្អិតនគរូបនីយកម្មត្រូវគោរពតាមផែនការប្រើប្រាស់ដី។

**ផែនការប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់** សំដៅដល់ផែនការប្រើប្រាស់ដីនៅក្នុងឃុំ សង្កាត់ទាំងមូល ទាំងដីរដ្ឋ ទាំងដីឯកជន ដោយប៉ាន់ប្រមាណពីសក្តានុពលដីនិងធនធានទឹក លទ្ធភាពផ្សេងៗក្នុងការប្រើប្រាស់ដី ព្រមទាំងលក្ខខណ្ឌសេដ្ឋកិច្ចនិងសង្គមកិច្ច ដើម្បីធ្វើការជ្រើសរើសនូវជម្រើសសមស្របក្នុងការប្រើប្រាស់ដី។

**ប្រភេទដីអាចសាងសង់បាន** សំដៅដល់ប្រភេទដីដែលជំរុញឱ្យមានការអភិវឌ្ឍនិងការសាងសង់លើគ្រប់វិស័យ។ ប្រភេទដីនេះ ត្រូវបានបែងចែកជាតំបន់លំនៅឋាន តំបន់ពាណិជ្ជកម្ម តំបន់ឧស្សាហកម្ម តំបន់ចម្រុះ តំបន់ដឹកជញ្ជូន តំបន់សេវាកម្មទេសចរណ៍ តំបន់រដ្ឋបាលនិងសេវាសាធារណៈ តំបន់លំហសាធារណៈ និងផ្ទៃបៃតង តំបន់វប្បធម៌និងសាសនា និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ប្រភេទដីកម្រិតការសាងសង់** សំដៅដល់ប្រភេទដីដែលត្រូវគ្រប់គ្រងពិសេសចំពោះការសាងសង់។ ប្រភេទដីនេះត្រូវបានបែងចែកជាតំបន់កសិកម្ម តំបន់ព្រៃឈើ តំបន់ធនធានទឹក តំបន់ការពារ និងតំបន់ផ្សេងៗមួយចំនួនទៀតស្របតាមភូមិសាស្ត្រជាក់ស្តែង។

**ផលធៀបផ្ទៃក្រឡាបាតសំណង់ធៀបនឹងផ្ទៃដីឡូត៍** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាបាតសំណង់ជាន់ផ្ទាល់ដី និងផ្ទៃក្រឡាដីឡូត៍ គិតជាភាគរយ។

**សន្ទស្សន៍ប្រើប្រាស់ដី** សំដៅដល់អនុបាតរវាងផ្ទៃក្រឡាកម្រាលសំណង់សរុបជាផ្លូវការ និងផ្ទៃក្រឡាដីឡូត៍ដែលសំណង់នោះតាំងនៅ។

**តំបន់ស្នូលនៃការអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់ ឬតំបន់ដែលមានការអភិវឌ្ឍខ្ពស់ សម្រាប់គាំទ្រដល់តំបន់ដែលមានសក្តានុពលទាប។

**អ័ក្សនៃការអភិវឌ្ឍ** សំដៅដល់បណ្តាញផ្លូវគមនាគមន៍ ឬច្រករបៀងតភ្ជាប់ពីតំបន់អភិវឌ្ឍន៍មួយទៅតំបន់អភិវឌ្ឍន៍មួយទៀត ដែលអាចឱ្យតំបន់ជាប់ជិតខាងតាមអ័ក្សទាញយកប្រយោជន៍ពីការអភិវឌ្ឍតាមអ័ក្សនេះបាន។

**ប៉ូលអភិវឌ្ឍ** សំដៅដល់តំបន់ដែលមានសក្តានុពលខ្ពស់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច។

**តំបន់លំហសាធារណៈនិងផ្ទៃបៃតង** សំដៅដល់តំបន់ដែលមានមុខងារសម្រាប់បម្រើដល់ការសម្រាក ការលំហែ ការកម្សាន្ត និងពិធីសាធារណៈនានាដូចជាឧទ្យាន សួនច្បារ សួនសត្វ សួនកុមារ កន្លែងក្មេងលេង សួនយុវជន សួនមនុស្សចាស់។ល។ ដែលត្រូវបានរៀបចំនិងសាងសង់សម្រាប់បម្រើដល់សាធារណជន។

**បណ្តាញបៃតង** សំដៅដល់សួនសាធារណៈ និងដើមឈើដែលរៀបចំប្រទាក់ក្រឡាគ្នាតាមចិញ្ចើមផ្លូវភ្ជាប់ទៅសួនទីក្រុង។

**ការត្រួតពិនិត្យការអភិវឌ្ឍ** សំដៅដល់ការត្រួតពិនិត្យការអនុវត្តស្របតាមប្លង់គោលប្រើប្រាស់ដី ផែនការប្រើប្រាស់ដី និងស្របតាមបទប្បញ្ញត្តិជាធរមាន។

**ឆ្នេរសមុទ្រ** សំដៅដល់ចំណែកដី ឬខ្សាច់ដែលមានសណ្ឋានជម្រាល និងលិចទឹកម្ដងម្កាល។ ឆ្នេរសមុទ្រត្រូវកំណត់ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតនៃទឹកសមុទ្រឡើងមកលើ រហូតដល់ខ្សែបន្ទាត់ហាមឃាត់ការកាន់កាប់ឬសាងសង់នានាជាថ្មី ដី ឬខ្សាច់ដែលបានកំណត់ទុកជាតំបន់សម្រាប់ ប្រើប្រាស់ជាសាធារណៈ និងត្រូវចាត់ថ្នាក់ជាដីសាធារណៈរបស់រដ្ឋ។ ទំហំឆ្នេរសមុទ្រត្រូវកំណត់ដូចខាងក្រោម៖

- ឆ្នេរជម្រាលត្រូវកំណត់យ៉ាងតិច៣០ (សាមសិប) ម៉ែត្រ ចាប់ពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុតទៅខាងដីគោក
- ឆ្នេរចោតត្រូវកំណត់យ៉ាងតិច២០(ម្ភៃ) ម៉ែត្រ ចាប់ពីចំណុចកំពូលនៃផ្ទៃចោតមកខាងដីគោក។

ក្នុងករណីដែលស្ថានភាពទីតាំងជាក់ស្ដែងនៃឆ្នេរជម្រាលមិនអាចកំណត់តាមទំហំខាងលើបាន ទំហំឆ្នេរសមុទ្រត្រូវកែច្នៃ ឬពង្រីកបន្ថែមដើម្បីបង្កើតជាឆ្នេរសម្រាប់ដើរលេងកម្សាន្តប្រសិនបើអាចធ្វើទៅបាន។

**ដីចំណីឆ្នេរសមុទ្រ** សំដៅដល់ផ្ទៃដីដែលចាប់រាប់ពីខ្សែបន្ទាត់ឆ្នេរខាងលើមកទិសខាងដីគោក។ ដីចំណីឆ្នេរសមុទ្រ ជាដីសាធារណៈរបស់រដ្ឋ លើកលែងតែមានការកាន់កាប់ស្របច្បាប់។ ប្រវែង ឬទំហំដីចំណីឆ្នេរសមុទ្រ ត្រូវកំណត់ដូចខាងក្រោម៖

- ប្រវែងទទឹងដីចំណីឆ្នេរសមុទ្រត្រូវកំណត់យ៉ាងតិច ៥០(ហាសិប) ម៉ែត្រគិតពីខ្សែបន្ទាត់ឆ្នេរខាងលើទៅខាងដីគោក
- ក្នុងករណីដែលតាមបណ្ដោយឆ្នេរសមុទ្រមានផ្លូវសាធារណៈរួចហើយ ដីចំណីឆ្នេរសមុទ្រអាចកំណត់មកទល់នឹងផ្លូវសាធារណៈនេះ។

**តំបន់រណប** សំដៅដល់តំបន់មួយប្លុកស្ថិតនៅចន្លោះផ្លូវសាធារណៈតាមបណ្ដោយឆ្នេរសមុទ្រ និងផ្លូវស្របបន្ទាប់មួយទៀតដែលស្ថិតក្នុងទិសខាងដីគោក។

**ផ្លូវសាធារណៈតាមបណ្ដោយដីចំណីឆ្នេរសមុទ្រ** សំដៅដល់ផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីឆ្នេរសមុទ្រដែលខណ្ឌចែកដីចំណីឆ្នេរសមុទ្រជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីឆ្នេរសមុទ្រ។

**ផ្លូវសាធារណៈតាមបណ្ដោយដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវាឬក្បូនចេញចូលបាន បណ្ដែតបាន** សំដៅដល់ផ្លូវដែលសាងសង់ឡើងនៅជាប់ខ្សែបន្ទាត់ខាងក្រៅនៃដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្ដែតបានទាំងនោះ ដែលខណ្ឌចែកដីចំណីដៃ សមុទ្រ ស្ទឹង ព្រែក ផ្លូវទឹក ដែលនាវា ឬក្បូនចេញចូលបាន បណ្ដែតបានជាមួយតំបន់រណប។ ផ្លូវនេះជារបាំងទប់ស្កាត់ការរំលោភបំពានកាន់កាប់ដីចំណីដៃសមុទ្រ ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្ដែតបាន។

**ដៃសមុទ្រ** សំដៅដល់ផ្ទៃទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ។ ទំហំផ្ទៃដៃសមុទ្រ ត្រូវកំណត់យកត្រឹមខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។ ទំហំដីចំណីដៃសមុទ្រត្រូវកំណត់ចម្ងាយ៣០(សាមសិប) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកជោរខ្ពស់បំផុត។

**ផ្លូវទឹកដែលតភ្ជាប់ទៅនឹងផ្ទៃទឹកសមុទ្រ** សំដៅដល់ស្ទឹង ព្រែក ផ្លូវទឹកដែលនាវា ឬក្បូនចេញចូលបាន បណ្តែតបាន។ ទំហំទទឹងស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ត្រឹមខ្សែបន្ទាត់កម្រិតទឹកខ្ពស់បំផុតទាំងសងខាងនៅរដូវវស្សា លើកលែងតែមានទឹកជំនន់ខុសធម្មតា។ ទំហំដីចំណីស្ទឹង ព្រែក ផ្លូវទឹកដែលនាវាឬក្បូនចេញចូលបាន បណ្តែតបាន ត្រូវកំណត់ចម្ងាយ ២០(ម្ភៃ) ម៉ែត្រយ៉ាងតិចពីខ្សែបន្ទាត់ទឹកខ្ពស់បំផុតនៅរដូវវស្សា។

**កោះ** សំដៅដល់ផ្ទៃដីដែលហ៊ុមព័ទ្ធដោយទឹកសមុទ្រ។ ព្រំប្រទល់ដីកោះក្នុងសមុទ្រ ត្រូវកំណត់ត្រឹមខ្សែទឹកជោរអតិបរមាឡើងលើ។ កោះអាចមានទំហំតូច ធំខុសៗគ្នា ដែលអាចប្រើប្រាស់ក្នុងគោលដៅផ្សេងៗ លើកលែងតែមានការកំណត់ដោយឡែក។ កោះអាចជាកម្មវត្ថុសម្រាប់ការរស់នៅនិងការអភិវឌ្ឍ ស្របតាមគោលដៅនៃការអភិវឌ្ឍសេដ្ឋកិច្ច សង្គមកិច្ច ការពារជាតិ និងទេសចរណ៍។

**ដែនទឹកសមុទ្រ** សំដៅដល់ផ្ទៃទឹកខាងលើនិងក្នុងទឹក។ នៅក្នុងទឹកមានធនធានសមុទ្រ ប្រព័ន្ធអេកូឡូស៊ីនិងជីវៈចម្រុះគ្រប់ប្រភេទ។

**អាងទន្លេ** សំដៅដល់តំបន់ភូមិសាស្ត្រដែលកំណត់ដោយព្រំប្រទល់ទីជម្រាលនៃប្រព័ន្ធទឹកហូរដោយរាប់ បញ្ចូលទាំងទឹកលើដី និងទឹកក្រោមដី។

**ទឹកក្រោមដី** សំដៅដល់ទឹកដែលហូរនៅក្រោមដីក្នុងចន្លោះថ្មតូចធំ និងភាគល្អិតនៃដីដែលផ្លាស់ទីពីកន្លែងមួយទៅកន្លែងមួយទៀត។

**សមុទ្រ** សំដៅដល់ប្រភពធនធានទឹកប្រៃ និងជាកន្លែងទទួលរំហូរទឹកមកពីទន្លេ ស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និងតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**ទន្លេ** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីស្ទឹង ព្រែក ជ្រោះ អូរ ទឹកក្រោមដី និង ពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅសមុទ្រ។

**ស្ទឹង** សំដៅដល់ផ្លូវទឹកធម្មជាតិ ដែលទទួលប្រភពទឹកមកពីជ្រោះ អូរ ទឹកក្រោមដី និងពីតំបន់ផ្ទៃរង ទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចាក់ទៅបឹង ទន្លេ និងសមុទ្រ។

**ព្រែក** សំដៅដល់ផ្លូវទឹកធម្មជាតិ ឬសិប្បនិម្មិតដែលនាំទឹកចេញឬចូលពីទន្លេ ឬស្ទឹង និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ។

**អូរ** សំដៅដល់ផ្លូវទឹកធម្មជាតិដែលទទួលប្រភពទឹកមកពីជ្រោះ និងពីតំបន់ផ្ទៃរងទឹកភ្លៀងនៅផ្នែកខាងលើ ហើយហូរចូលព្រែក ស្ទឹង ទន្លេ ឬបឹង។

**ជ្រោះ** សំដៅដល់ជ្រលង ឬល្បាក់ទឹកធម្មជាតិដែលកើតឡើងដោយសារបាតុភូតធម្មជាតិនៃការហូរច្រោះ ដោយសារចរន្តទឹកពីតំបន់ភ្នំ ឬតំបន់ខ្ពង់រាប។

**បឹងបួរ** សំដៅដល់ល្អាលទឹកធំល្វឹងល្វើយកើតពីទីជម្រាល ឬជម្រៅធម្មជាតិដែលអាចមានទឹក ឬគ្មានទឹកទៅតាមរដូវកាល និងមានប្រភពមកពីទន្លេ ស្ទឹង ព្រែក ឬពីតំបន់ផ្ទៃរងទឹកភ្លៀង។

**អាងទឹក** សំដៅដល់ទីតម្កល់ទឹកដែលកើតឡើងដោយធម្មជាតិ ឬសិប្បនិម្មិតសម្រាប់ប្រើទៅតាមតម្រូវការ។

**ប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់** សំដៅដល់ប្រឡាយចំហ អាងស្តុក ស្ថានីយបូមលូ ឬទឹកភ្លៀង បណ្តាញលូមេ បណ្តាញលូមេរង ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួមមានតាមលក្ខណៈបច្ចេកវិទ្យា ឬលក្ខណៈធម្មជាតិ។

**ស្ថានីយ៍ប្រព្រឹត្តកម្មទឹកកខ្វក់រួម** សំដៅដល់រោងចក្រកសម្អាតទឹកកខ្វក់រួមរបស់ទីប្រជុំជន រាជធានី ខេត្ត ក្រុង ស្រុក ឬខណ្ឌ។

**ទឹកកខ្វក់** សំដៅដល់ទឹកដែលបានប្រែប្រួលចរិតលក្ខណៈដើមរបស់វា ក្រោយពីការប្រើប្រាស់រួចមានដូចជា ទឹកសំណល់ពីផ្ទះបាយ បន្ទប់ទឹក ការបោកគក់ ឬការលាងសម្អាតនានា និងទឹកសំណល់ពីបង្គន់អនាម័យរួមទាំងទឹកនោម និងលាមកដែលបញ្ចេញពីលំនៅឋាន បុរីលំនៅឋាន ទីក្រុងរណប អគារអាជីវកម្ម អគារពាណិជ្ជកម្ម សេវាកម្ម និងតំបន់ទីរមនីយដ្ឋាន ឬមជ្ឈមណ្ឌលកំសាន្ត។

**សំណល់រាវ** សំដៅដល់ទឹកសំណល់មានផ្ទុកសារធាតុបំពុលបរិស្ថានដែលបញ្ចេញពីសកម្មភាព ឬដំណើរការផ្ទាល់នៃផលិតកម្ម អាជីវកម្ម ឬសេវាកម្ម។

**ប្រព័ន្ធលូ** សំដៅដល់បណ្តាញប្រមូល និងបង្ហូរទឹកកខ្វក់រួមមាន៖ តំណភ្ជាប់ អណ្តូងលូ និងបណ្តាញលូ (បណ្តាញលូរួម បណ្តាញលូដាច់ដោយឡែក បណ្តាញលូមេ បណ្តាញលូមេរង បណ្តាញលូខ្នែង និងបណ្តាញលូខ្នែងរង)។

**អាងបង្គន់អនាម័យ** សំដៅដល់អាងទទួលទឹកកខ្វក់ពីបង្គន់អនាម័យ និងបន្ទប់ទឹក ដើម្បីស្តុក និងបំបែកសំណល់សរីរាង្គក្នុងទឹកកខ្វក់ មុនការហូរចេញទៅក្នុងប្រព័ន្ធលូសាធារណៈ។

**ឯកសារឧបសម្ព័ន្ធ**

- របាយការណ៍បច្ចេកទេស
- ផែនទីយុទ្ធសាស្ត្ររៀបចំដែនដីនិងនគរូបនីយកម្ម
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យឧស្សាហកម្ម
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍវិស័យទេសចរណ៍
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ បច្ចេកទេស និងសេវាកម្ម
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ផែនទីយុទ្ធសាស្ត្រការពារបរិស្ថាននិងធនធានធម្មជាតិ
- ផែនទីយុទ្ធសាស្ត្រអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គម។